# មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

# វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

## សេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ូម តំបន់ទី ៦

## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

## ថ្ងៃច័ន្ទ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦

## ខេត្តក្រចេះ

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

០១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក **ឡារី ស្ត្រេនន្ទ (Larry Strange)** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

០២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ុម (COPCELPROM) ដោយលោក **ឱក សេរី សោភក្តិ** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

០៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក **អ៊ុង ស៊ីយឿន** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តក្រចេះ

០៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តក្រចេះ

០៥. សេចក្តីផ្សេងៗ

### ០១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក ឡារី ស្ត្រេនន្ទ (Larry Strange) នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

វិទ្យាស្ថាន CDRI មានមោទនៈភាពដែលបានរៀបចំកិច្ចប្រជុំខប់សែលទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត ដែលដំណើរការនៃកិច្ចប្រជុំគឺជាឆន្ទះមួយដើម្បីកសាងឱ្យមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ជាពិសេសឆ្ពោះទៅរកការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ។ វិទ្យាស្ថាន CDRI បានកត់សំគាល់ឃើញថា កិច្ចប្រជុំខប់សែលថ្នាក់ខេត្តនីមួយៗគឺមានការចូលរួមយ៉ាងផុលផុសពីសំណាក់លោកស្រីអស់លោកដែលនៅក្នុងមូលដ្ឋានផ្ទាល់ ហើយបានលើកឡើងនូវបញ្ហាជាក់ស្តែងច្រើនដោយត្រង់ទៅត្រង់មក និងដោយជំហរ ។ ក្នុងនាមវិទ្យាស្ថាន CDRI លោកសង្ឃឹមថាការប្រជុំនេះនឹងមានសភាពដូចគ្នានៅតាមខេត្តផ្សេងៗដែរ ។ លោកក៏បានសូមថ្លែងអំណរគុណដល់ក្រសួងមហាផ្ទៃដែលបានអនុញ្ញាតឱ្យកម្មវិធីខប់សែលមានដំណើរការរហូតមកដល់ពេលនេះ ជាពិសេសសូមថ្លែងអំណរគុណចំពោះឯកឧត្តមអភិបាលខេត្ត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ខេត្ត ដែលបានគាំទ្រចំពោះយន្តការខប់សែល និងអនុញ្ញាតឱ្យមានការរៀបចំកិច្ចប្រជុំនេះ ។

ឆ្លៀតក្នុងឱកាសនោះលោកក៏សូមថ្លែងអំណរគុណដល់លោក អ៊ុង ស៊ីយឿន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តក្រចេះ លោក គីមអឿន មកពីខាង CCD លោកស្នងការ និងស្នងការរង និងគ្រប់តំណាងគណបក្សនយោបាយ តំណាងអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធក្នុងការងារបោះឆ្នោត ដែលបានចូលរួមយ៉ាងសកម្មគាំទ្រ និងសហការក្នុងការរៀបចំកិច្ចប្រជុំនេះឱ្យទទួលបានជោគជ័យ ។ ជោគជ័យរបស់ខប់សែល គឺអាស្រ័យលើការចូលរួមរបស់លោកស្រី អស់លោកដែលជាភាគីពាក់ព័ន្ធនៅក្នុងការងារបោះឆ្នោត ។

ក្នុងនាមវិទ្យាស្ថាន CDRI សូមថ្លែងអំណរគុណដល់អ្នកស្រី Margie Cook ទីប្រឹក្សាបច្ចេកទេសផ្នែកបោះឆ្នោត នៃអង្គការសហប្រជាជាតិផ្នែកកម្មវិធីអភិវឌ្ឍន៍ (UNDP) ចំពោះរាល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុចំពោះយន្តការខប់សែល ។ លោកនឹងបង្ហាញថា ហេតុអ្វីបានជាខប់សែលមានសារៈសំខាន់សំរាប់វិទ្យាស្ថាន CDRI ។

វិទ្យាស្ថាន CDRI គឺជាស្ថាប័នស្រាវជ្រាវឯករាជ្យអំពីគោលនយោបាយអភិវឌ្ឍន៍នានានៅក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដែលវិទ្យាស្ថានមានឆន្ទៈយ៉ាងមុតមាំក្នុងការជួយជំរុញធ្វើឱ្យកាន់តែប្រសើរឡើង នៅដំណើរការនៃការរៀបចំការបោះឆ្នោតនៅកម្ពុជា

។ វិទ្យាស្ថាន CDRI ជឿជាក់ថារាល់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព គឺអាស្រ័យលើការអភិវឌ្ឍន៍ផ្នែកអភិបាលកិច្ចល្អ មានដំណើរការល្អនៃការរៀបចំការបោះឆ្នោត មានតម្លាភាព និងយុត្តិធម៌ ។ វិទ្យាស្ថាន CDRI ជឿថាដំណើរការនៃការបោះឆ្នោតដ៏ត្រឹមត្រូវ និងយុត្តិធម៌គឺជាក្បាលម៉ាស៊ីនមួយដែលនាំឱ្យមានការអភិវឌ្ឍន៍ ជាពិសេសធ្វើឱ្យមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ។ លោកសង្ឃឹមកិច្ចប្រជុំនេះនឹងមានការពិភាក្សាប្រកបដោយជំហរ ត្រង់ទៅត្រង់មក និងដោយការយោគយល់គ្នា ដើម្បីលើកបញ្ហាដោះស្រាយចំពោះមុខគ្នាទៅវិញទៅមក និងសូមជូនពរឱ្យកិច្ចប្រជុំនេះប្រកបដោយផ្លែផ្កា ។

**អ្នកស្រី Margie Cook** តំណាងអង្គការ UNDP មានសេចក្តីរីករាយ និងមានចំណាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងការគាំទ្រចំពោះយន្តការខប់សែល ដើម្បីឱ្យមានដំណើរការបន្តជានិច្ចនៅក្នុងការចូលរួមលើកស្ទួយ ដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតប្រសើរឡើង ជាពិសេសតាមរយៈការរៀបចំកិច្ចប្រជុំទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត ។ UNDP មានចំណាប់អារម្មណ៍និងបានចូលរួមយ៉ាងសកម្មនៅក្នុងការគាំទ្រដំណើរការបោះឆ្នោត ជាពិសេសបានគាំទ្រចំពោះយន្តការខប់សែល និងស្ថាប័នផ្សេងៗទៀតដែលធ្វើការពាក់ព័ន្ធនិងការងារបោះឆ្នោត ជាពិសេសទៀត UNDP បានគាំទ្រដល់ គជប នៅក្នុងដំណើរការនៃការរៀបចំនេះដែលបានគាំទ្រលើកំណែទម្រង់ផ្នែកច្បាប់ ផ្តល់ការបណ្តុះបណ្តាល និងផ្តល់ជាបច្ចេកទេសផ្សេងៗទៀត ។ នៅក្នុងការគាំទ្រចំពោះដំណើរការនៃការរៀបចំអ្នកបោះឆ្នោត UNDP បានគាំទ្រលើចំណុច៤ ទី១ ទាក់ទងដំណើរការនៃការចុះបញ្ជីឈ្មោះបោះឆ្នោត ទី២ ពាក់ព័ន្ធនិងការអប់រំ ទី៣ ទាក់ទងនិងការផ្សព្វផ្សាយជាសាធារណៈ តាមរយៈប្រព័ន្ធពត៌មាន ទី៤ ជាពិសេសគាំទ្រចំពោះស្ថាប័នសង្គមស៊ីវិល អង្គការក្រៅរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនិងការងារបោះឆ្នោត ។ អ្នកស្រីបានចំណាយពេលជាង ៦ឆ្នាំធ្វើការនៅ UNDP នៅអាហ្វ្រិចខាងត្បូងដែលពាក់ព័ន្ធនិងរឿងការងារបោះឆ្នោតនេះ យើងឃើញថាដំណើរការនៃការរៀបចំមានបញ្ហាដូចៗគ្នា ហើយបញ្ហាទំនាស់ផ្សេងៗដែលកើតមាននៅពេលរៀបចំការបោះឆ្នោត ។ នៅប្រទេស Tanzania នៅអាហ្វ្រិចខាងត្បូង ដំណើរការនៃការរៀបចំការបោះឆ្នោត ខាង UNDP ក៏បានធ្វើការទៅលើកម្មវិធី ២សំខាន់ **ទី១** ទាក់ទងនិងការទប់ស្កាត់ទំនាស់ក្នុងពេលបោះឆ្នោត ដែលធ្វើការជាមួយនិងតំណាងគណបក្សនយោបាយ ដោយបង្កើតកម្មវិធីពិភាក្សាជាមួយតំណាងគណបក្សនយោបាយ និងតំណាងប៉ូលីស **ទី២** ទាក់ទងនិងការពិភាក្សារវាងអ្នកសារព័ត៌មាន និងគណបក្សនយោបាយ បើសិនជាគ្មានគណបក្សនយោបាយធ្វើកិច្ចពិភាក្សាមានការពិបាក ។

អ្វីដែលអ្នកស្រីមានការចាប់អារម្មណ៍ គឺខប់សែលបានបញ្ចូលគ្រប់ភាគីពាក់ព័ន្ធនានានៅក្នុងស្ថាប័នជាតិ និងថ្នាក់ខេត្តទាំងអស់មិនចំពោះតែខាងគណបក្សនយោបាយ សង្គមស៊ីវិល អាជ្ញាធរ សូម្បីតែខាងប៉ូលីសក៏បានចូលរួមដែរ ។ ដូច្នេះវេទិការនេះគឺផ្តល់ឱកាសជូនដល់លោកស្រី អស់លោក លើកឡើងនូវបញ្ហា ជាពិសេសជំរុញឱ្យមានការពិភាក្សាលើបញ្ហានានាដែលកើតមានជុំវិញការរៀបចំការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជា ។ អ្នកស្រីសង្ឃឹមថាប្រទេសផ្សេងទៀតដែលមានសភាពប្រហាក់ប្រហែលនិងប្រទេសកម្ពុជាអាច រៀនសូត្រពីបទពិសោធន៍នៃការរៀបចំកិច្ចប្រជុំខប់សែលនេះ ដើម្បីយកទៅអនុវត្តឱ្យបានកាន់តែប្រសើរនៅប្រទេសផ្សេងៗទៀត ។ ចំពោះតួនាទីរបស់អ្នកស្រីនៅក្នុងកិច្ចប្រជុំនេះ គ្រាន់តែស្តាប់ការពិភាក្សារបស់អង្គប្រជុំ និងរៀនសូត្រពីកិច្ចប្រជុំនេះ ។ អ្នកស្រីបានជូនពរឱ្យកិច្ចប្រជុំនេះប្រកបទៅដោយផ្លែផ្កា ។

### ០២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ុម (COPCELPROM) ដោយលោក ឱក សេរី សោភគ្គី ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

**លោក ឱក សេរី សោភគ្គី** បានថ្លែងអំណរគុណដល់អ្នកស្រី Margie Cook ដែលបានចូលរួមនៅក្នុងយន្តការខប់សែលប្រ៉ុមនេះនៅកន្លែងផ្សេងៗទៀត UNDP ក៏បានចូលរួមដែរ តែលើកនេះអ្នកស្រីបានចូលរួមហើយបានជំរាបយើងអំពីកម្មវិធីដែល UNDP

កំពុងតែធ្វើ ។ លោកជឿថាមានរឿងច្រើនណាស់ដែលអ្នកស្រីមានប្រសាសន៍មកតែយើងមិនបានដឹង ដូច្នេះនេះជាការសំខាន់ណាស់ យើងដឹងថា UNDP ជួយច្រើនណាស់ តែយើងមិនដឹងថាជួយកន្លែងណា ជួយធ្វើអ្វី ជួយនៅពេលណា ។ លោកសង្ឃឹមថា UNDP នឹងធ្វើបែបនេះយកគំរូតាមអ្នកស្រីដោយមានការចូលរួមនៅថ្នាក់ខេត្ត ដើម្បីឱ្យប្រជាពលរដ្ឋដឹងថា UNDP បានធ្វើអ្វីខ្លះ ។ ប្រសាសន៍ចុងក្រោយរបស់អ្នកស្រីធ្វើឱ្យយើងមានភាពកក់ក្តៅក្នុងអារម្មណ៍ណាស់ ដែលថាប្រទេសឯទៀតៗដែលទើបតែចេញពីសង្គ្រាម គឺអាចនឹងរៀនសូត្រ យកគំរូតាម យន្តការខប់សែលរបស់យើង ។ នេះជាមោទនៈភាពជាតិដែលយើងគ្រាន់តែចេញពីសង្គ្រាមកាលពីឆ្នាំ ១៩៩៨ យើងនៅក្មេងខ្ចីណាស់ តែយើងអាចបង្កើតនៅយន្តការមួយជជែកពិភាក្សាគ្នា ហើយអាចផ្តល់នូវមេរៀន បទពិសោធន៍ដល់ប្រទេសឯទៀតៗបាន ។ មោទនៈភាពនេះគឺបានពីលោកស្រី អស់លោក ទាំងអស់គ្នានេះ ។ លោកបានជំរាបជូនពីប្រវត្តិខ្លះៗនៃយន្តការនេះ ។

នៅពេលដែលមានសង្គ្រាម លោកផ្ទាល់បានធ្វើការតស៊ូនៅជាយដែន ហើយឃើញការស្លាប់ច្រើនណាស់ ដូចយើងដឹងហើយថាប្រទេសយើងល្បីណាស់រឿងអង្គរវត្តដែលល្អជាងគេក្នុងពិភពលោក ហើយក៏ល្បីទាំងការសម្លាប់រង្គាលដែលសាហាវនៅក្នុងពិភពលោកផងដែរ ។ នៅក្នុងព្រៃជាង ១១ឆ្នាំ លោកបានគិតថាដោយធ្លាប់បានឆ្លងកាត់លោកស្អប់សង្គ្រាម ស្អប់អាវុធ ស្អប់អំពើហិង្សា លោកចេះតែគិតថាធ្វើយ៉ាងណាដើម្បីឱ្យសង្គមខ្មែរ ឱ្យកូនចៅជំនាន់ក្រោយកុំឱ្យស្គាល់យុគខ្មៅងងឹតដូចមុនទៀត ។ ចេញពីនោះមកលោកបានមកធ្វើជាទីប្រឹក្សា និងនាយកខុទ្ទកាល័យរបស់ឯកឧត្តម ស ខេង ពីឆ្នាំ ១៩៩៣-១៩៩៩ លោកបានជួយនៅក្នុងរឿងយន្តការបោះឆ្នោត ។ យើងបានគិតបញ្ហារៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់តាំងពីឆ្នាំ ១៩៩៤ មកម្ល៉េះ ព្រោះបំរុងធ្វើនៅឆ្នាំ ២000 ប៉ុន្តែដោយព្រឹត្តិការណ៍ចេះតែជំរុញរហូតដល់ឆ្នាំ ២០០២ ។ កាលបោះឆ្នោតឆ្នាំ ១៩៩៨ មានបញ្ហាច្រើនរហូតដល់មានការបង្ហាញរូបភាពហិង្សានៅក្នុងសកលលោកឱ្យឃើញ ។ ក្រោយមកលោកចង់បានបទពិសោធន៍ជាមួយនិងអង្គការក្រៅរដ្ឋាភិបាល លោកក៏បានមកធ្វើការជាមួយ CDRI ជាអ្នកសំរបសំរួលកម្មវិធីសន្តិភាព និងអភិវឌ្ឍន៍ ពេលនោះហើយដែលយើងបានធ្វើការស្រាវជ្រាវថា តើអំពីហិង្សាកាលពីឆ្នាំ ១៩៩៨ កើតមកពីអ្វី? ។ ពេលដែលរកឃើញដើមហេតុ ៦-៧ធំៗ លោកស្រម័យឃើញយន្តការ ។ សង្គមខ្មែរយើងចូលចិត្តនិយាយល្អនៅមុខគ្នា ប៉ុន្តែនៅពីក្រោយចូលចិត្តនិយាយដើមគ្នាណាស់ ។ ដើម្បីបង្ការទំនាស់បានមានតែយកតួអង្គទាំងអស់មកអង្គុយនៅជុំវិញតុដើម្បីលើកបញ្ហាក្តៅគគុកទាំងប៉ុន្មានមកជជែកត្រង់ទៅត្រង់មក បង្កើតវប្បធម៌ពិភាក្សាថ្មីមួយ ដែលមិនធ្លាប់មានពីមុនមកហើយបញ្ហាកាន់តែក្តៅគគុកកាន់តែយកមកដាក់លើតុជជែកគ្នា ។

ដូច្នេះពីឆ្នាំ ១៩៩៩-២០០៣ CDRI បានរៀបចំខប់សែលដំណាក់កាលទី១ ក្នុងមួយខែប្រជុំគ្នាម្តងទាំងអស់ប្រជុំ ៥០ ដង មិនដែលបាត់ទេ ទោះបីជាស្ថានការណ៍ក្តៅគគុកយ៉ាងណាក៏មិនដែលរំលងទេ ។ យើងទទួលបានជោគជ័យរាជរដ្ឋាភិបាលទទួលស្គាល់ព្រះមហាក្សត្រ សម្តេចនាយក ឯកឧត្តមឧប ក៏គាំទ្រ យើងក៏បានរៀបចំនៅឆ្នាំ ២០០២-២០០៣ ជួយ គជប ។ យើងបានបញ្ចប់យន្តការខប់សែលដំណាក់កាលទី១នៅឆ្នាំ ២០០៣ ។

នៅពេលដែលរៀបចំការបោះឆ្នោតសំរាប់ឆ្នាំ ២០០៧-២០០៨ UNDP បានឃើញរបាយការណ៍របស់ខប់សែល ហើយថាយន្តការនេះល្អណាស់ដែលត្រូវតែបន្តទៅទៀត ដើម្បីបំរើការបោះឆ្នោតឆ្នាំ ២០០៧-២០០៨ ។ លោក Douglas gardner ប្រធាន UNDP បានជួបលោកឡារី ស្រ្តែន្ទ និងរូបលោកផ្ទាល់ក៏បានស្នើសុំឱ្យ CDRI បន្តយន្តការខប់សែលបន្តទៀតនៅក្នុងដំណាក់កាលទី២ ។ លោកបានគិតថាធ្វើយ៉ាងម៉េចដើម្បីឱ្យមានប្រសិទ្ធិភាពជាងដំណាក់កាលទី១ ក៏បានឃើញថារឿងទំនាស់ដែលកើតឡើង គឺកើតឡើងនៅថ្នាក់មូលដ្ឋាន បើយើងដោះស្រាយ និងបង្ការបាននៅថ្នាក់មូលដ្ឋាន បញ្ហាមិនអាចឡើងដល់លើបានទេ អញ្ចឹងយើងក៏បង្វែរទិសដៅខប់សែលដែលឱ្យសារៈសំខាន់នៅថ្នាក់ជាតិ យកមកឱ្យមានសារៈសំខាន់នៅថ្នាក់មូលដ្ឋាន ទើបមានខប់សែលប្រ៊មនេះកើតឡើង ។

យើងចង់ស្តាប់សំដីបងៗដែលជាសមាជិកក្រុមប្រឹក្សាឃុំ ព្រោះគាត់នៅជាប់ជាមួយប្រជាពលរដ្ឋ ស្គាល់បញ្ហាទំនាស់អ្វីខ្លះដែលកើតមានតាំងពីដំណាក់កាលចុះឈ្មោះបោះឆ្នោត ដំណាក់កាលគណបក្សនយោបាយ ដំណាក់កាលប្រកាសបេក្ខជន ដំណាក់កាលយុទ្ធនាការឃោសនា ដំណាក់កាលបោះឆ្នោត រាប់សន្លឹកឆ្នោត និងដំណាក់កាលប្រកាសលទ្ធផល ។ គ្រប់ដំណាក់កាលនេះហើយបើយើងគ្រប់គ្រងដំណាក់កាលនេះបានរឿងនោះនឹងលែងទៅជានយោបាយហើយ នាំឱ្យការបោះឆ្នោតនិងនយោបាយនៅដាច់ពីគ្នា មិនមានជាប់តាំងដូចការមុនទេ ។

ខប់សែលមានគោលបំណងចង់បណ្តុះវប្បធម៌នៃការជជែកពិភាក្សាគ្នាត្រង់ទៅត្រង់មកនៅលើតុ ដើម្បីសំរេចគោលដៅ ៣ ធំៗ **ទី១** ចង់ឱ្យប្រជាពលរដ្ឋខ្មែរ ជាពិសេសជំនាន់ក្រោយកើតមកពេលដល់អាយុ ១៨ ឆ្នាំគាត់ទៅចុះឈ្មោះដោយខ្លួនឯង ។ **ទី២** ចង់ឱ្យប្រជាពលរដ្ឋដែលមានអាយុ១៨ ហើយមានសិទ្ធិទទួលអត្តសញ្ញាណប័ណ្ណជាតិ ។ **ទី៣** យើងនិងរួមគ្នាជជែកធ្វើយ៉ាងណាដើម្បីពេលបោះឆ្នោតម្តងៗគឺជាពេលដែលមានសុវត្ថិភាព គឺជាពេលដែលយើងធ្វើការពង្រឹងលទ្ធិប្រជាធិបតេយ្យដែលជាលក្ខខ័ណ្ឌមិនអាចខ្វះបានក្នុងការអភិវឌ្ឍន៍ឱ្យមានចិរភាព និងនិរន្តភាពនៅក្នុងប្រទេសកម្ពុជា ។

## ០៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក អ៊ុង ស៊ីយឿន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តក្រចេះ

**លោក អ៊ុង ស៊ីយឿន** បានជំរាបពីស្ថានភាព ២ ទៅអង្គប្រជុំ ទី១ ស្ថានភាពទូទៅរបស់ខេត្តក្រចេះ ទី២ ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតរបស់ខេត្តក្រចេះដោយគិតពីឆ្នាំ ១៩៩៣មក ។

**ទី១** ខេត្តក្រចេះស្ថិតនៅភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា មានផ្ទៃដីសរុប ១១ ០៩៤ $Km^2$ ចែកចេញជាដីព្រៃចំនួន ៨៣.៥% ដីក្រហម ០.៥% ដីសើម ៣% និង១៣%ជាដីសាងសង់លំនៅដ្ឋាន ។ មានស្រុកចំនួន ៥ ចែកចេញជា ៤៦ឃុំ និង ២៥០ ភូមិ មានប្រជាពលរដ្ឋសរុបចំនួន ២៨៦ ៦៨៩ នាក់ ប្រជាពលរដ្ឋអាយុ ១៨ឡើងមានចំនួន ១៥៦ ៣៨៥ នាក់ ក្នុងនោះស្រីចំនួន ៧៩ ៩៦០ នាក់ មានដង់ស៊ីតេប្រជាពលរដ្ឋចំនួន ២.៥នាក់ក្នុង ១$Km^2$ ទីតាំងរដ្ឋបាលស្រុកស្ថិតនៅតាមបណ្តោយទន្លេមេគង្គចំនួន ៤ស្រុកដែល ១ស្រុកទៀតស្ថិតនៅឆ្ងាយពីទីរួមខេត្តជាប់និងផ្លូវជាតិលេខ ៧ ។ ទីតាំងឃុំមួយចំនួនស្ថិតនៅឆ្ងាយដាច់ស្រយាលពីទីរួមស្រុក ត្រូវឆ្លងព្រែក ទន្លេ អូរ ជាច្រើនកន្លែងនិងមិនមានសេវាទូរសព្ទ ។ ប្រជាពលរដ្ឋភាគច្រើនមានមុខរបរជាកសិករ ច្រើនតាំងទីលំនៅតាមដងទន្លេមេគង្គដែលមានអំណោយផលខាងកសិកម្ម និងនេសាទ បច្ចុប្បន្នកំពុងមានការអភិវឌ្ឍន៍ជាបន្តបន្ទាប់ ។

**ទី២** ចាប់តាំងពីឆ្នាំ ១៩៩៣ មក ខេត្តក្រចេះបានរៀបចំបោះឆ្នោតចំនួន ៥ដងរួចមកហើយ ទី១ ឆ្នាំ ១៩៩៣ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី១ ដែលរៀបចំដោយអ៊ុនតាក់ ៤លើកទៀតរៀបចំដោយគណកម្មាការរៀបចំការបោះឆ្នោតខេត្តក្រចេះដែលមាន គជប ជាអ្នកគ្រប់គ្រង និងដឹកនាំ ។ ឆ្នាំ ១៩៩៨ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី២ ។ ឆ្នាំ ២០០២ បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំអាណត្តិទី១ ។ ឆ្នាំ ២០០៣ បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៣ ។ ឆ្នាំ ២០០៦ បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ ។ បច្ចុប្បន្នកំពុងរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំអាណត្តិទី២ ដែលនឹងប្រព្រឹត្តនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៧ ។

ជាការពិតណាស់ថាការរៀបចំបោះឆ្នោតជ្រើសតាំង ឬជ្រើសរើសអ្នកតំណាងប្រជាពលរដ្ឋ គឺជាវិធីមួយដ៏ល្អមានតែមួយគត់ដើម្បីឱ្យប្រជាពលរដ្ឋមានឱកាសសំដែងនៅការគាំទ្រចំពោះគណបក្សនយោបាយ ឬអ្នកដឹកនាំដែលគាត់ស្រឡាញ់ ហើយក៏ជាឱកាសដែលបណ្តាលគណបក្សនយោបាយបានចូលរួមប្រកួតប្រជែងដោយយុត្តិធម៌ ដើម្បីទទួលបានប្រជាប្រិយភាព ។ ដូចនេះទាមទារនៅ

សមត្ថភាព វិជ្ជាជីវៈ និងការទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់ដែលចាំបាច់ត្រូវមាន ទី១ ធនធានមនុស្ស ទី២ ប្រព័ន្ធច្បាប់ ប្រព័ន្ធនីតិវិធីមួយដែលមានសុក្រិត្យភាព ហើយឆ្លើយតបទៅនិងសេចក្តីត្រូវការរបស់ភាគីដែលពាក់ព័ន្ធទាំងអស់ និងទី៣ ធនធានហិរញ្ញវត្ថុ ដែលមានលក្ខណៈសមស្របទៅនិងទំហំនៃការងារ ។

ក្នុងន័យនេះលោកសូមសំដែងនូវមោទនៈភាពដ៏ជ្រាលជ្រៅដែលជាតិយើងអាចបំពេញការងារដ៏ធំធេង មានលក្ខណៈស្មុគ្រស្មាញប្រកបដោយជោគជ័យជាបន្តបន្ទាប់មក ។ សមិទ្ធិផលជាតិក៏ដូចជាផ្លែផ្កានៃលទ្ធិប្រជាធិបតេយ្យដែល គជប បានពុះពារសំរេចបានកន្លងមក ហើយបច្ចុប្បន្នកំពុងអនុវត្តឱ្យកាន់តែប្រសើរថែមទៀតនោះ គឺសមដូចសេចក្តីថ្លែងការចុះថ្ងៃទី ៣0 ខែកក្កដា ឆ្នាំ ២00៣ របស់ក្រុមបេសកម្មសង្កេតការបោះឆ្នោតនៅកម្ពុជាមកពីសហគមន៍អឺរ៉ុប ដែលដឹកនាំដោយឯកឧត្តម Robet Avent និង ឯកឧត្តម Kli fort សមាជិកសភាសហគមន៍អឺរ៉ុប បានកត់សំគាល់ថាដំណើរការបោះឆ្នោតប្រព្រឹត្តទៅបានល្អច្រើន ។ ដំណើរការនៅថ្ងៃបោះឆ្នោតប្រព្រឹត្តទៅដោយរលូន ដោយមានអ្នកបោះឆ្នោតចូលរួមស្ងៀមស្ងាត់ ការរៀបចំប្រកបដោយបច្ចេកទេសល្អបានយកឈ្នះលើអាកាសធាតុមិនអនុគ្រោះ ។

ដើម្បីឱ្យអង្គប្រជុំសិក្សាស្វែងយល់កាន់តែស៊ីជំរៅនៅការរៀបចំការបោះឆ្នោតថែមទៀត លោកបានលើកឡើងនូវចំណុចវិជ្ជមានមួយចំនួននៃការរៀបចំការបោះឆ្នោត ដោយប្រៀបធៀបពីឆ្នាំ ២00៣ រហូតដល់បច្ចុប្បន្ន ។ ចំណុចសំខាន់ៗរួមមាន **ទី១** ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត ចាប់តាំងពីឆ្នាំ ២00៤ មក គជប បានតំរូវឱ្យអនុវត្តធ្វើបច្ចុប្បន្នភាពបញ្ជី ដោយចាប់ផ្តើមពីថ្ងៃទី0១ តុលា រៀងរាល់ឆ្នាំ ហើយបានបន្ថែមឱ្យមានការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះត្រៀមដែលចាប់ផ្តើមពីថ្ងៃទី0១ មករា រហូតដល់ 0៣ កញ្ញាជារៀងរាល់ឆ្នាំ ។ **ទី២** ការអប់រំបណ្តុះបណ្តាល និងព័តិមានសាធារណៈ ចាប់តាំងពីឆ្នាំ ២00៤ មក គជប បានតំរូវឱ្យមានការបណ្តុះបណ្តាលមានលក្ខណៈទូលំទូលាយ ដោយភាគីដែលពាក់ព័ន្ធទាំងអស់អាចចូលរួមទទួលការបណ្តុះបណ្តាលបានទាំងនៅថ្នាក់ជាតិ ក៏ដូចជានៅថ្នាក់ខេត្ត ។ គជប បានផលិតប័ណ្ណព័តិមានអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតចែកជូនដល់សាម៉ីអ្នកបោះឆ្នោតទាំងអស់ ហើយកំពុងត្រៀមផ្តល់ប័ណ្ណព័តិមានមុនថ្ងៃបោះឆ្នោតជាបន្ថែមទៀត ។ **ទី៣** ការរៀបចំគណកម្មាការការិយាល័យបោះឆ្នោតនៅសម័យបោះឆ្នោតឆ្នាំ ២00៧ ខាងមុខនេះគណកម្មាការការិយាល័យបោះឆ្នោត គជប តំរូវឱ្យមានចំនួន ៦នាក់ ដែលពីមុនមានតែ ៥នាក់ ដើម្បីឱ្យម្នាក់ក្នុងចំណោមសមាជិកទាំង ៦នាក់នោះជាអ្នកជួយដល់ប្រជាពលរដ្ឋក្នុងការរកឈ្មោះ ឬទីតាំងការិយាល័យបោះឆ្នោត ។

ចំណុចវិជ្ជមានដែលលោកបានជំរាបជូនអង្គប្រជុំទាំងអស់នេះ គឺជាការខិតខំប្រឹងប្រែងបន្ថែមទៀតលើផែនការសកម្មភាពដែលមានស្រាប់របស់ គជប សំដៅធ្វើឱ្យការរៀបចំបោះឆ្នោតកាន់តែល្អប្រសើរឡើង ប៉ុន្តែជាការពិតទោះបីការកសាងផែនការប្រកបដោយភាពសុក្រិត្យ និងមានលក្ខណៈល្អិតល្អន់យ៉ាងណាក៏មិនអាចជៀសផុតពីភាពខ្វះចន្លោះនៅពេលអនុវត្ត ។ ហេតុនេះលោកសូមស្វាគមន៍ដោយរីករាយចំពោះការផ្តួចផ្តើមកិច្ចប្រជុំថ្ងៃនេះ ដើម្បីរួមគ្នាពិនិត្យមើលឡើងវិញនៅអ្វីដែលសេសសល់ ក៏ដូចជារួមគ្នាពិនិត្យមើលថាតើមានអ្វីដែលអាចនិងកើតឡើង ដើម្បីពិភាក្សា និងរកដំណោះស្រាយ ។

តាងនាមឱ្យគណកម្មាការរៀបចំការបោះឆ្នោតខេត្តក្រចេះ លោកសូមថ្លែងអំណរគុណចំពោះអាជ្ញាធរខេត្ត ស្រុក ឃុំ កងកំលាំងគ្រប់ប្រភេទ អង្គការក្រៅរដ្ឋភិបាលទាំងអស់ ដែលជានិច្ចកាលតែងតែផ្តល់នូវកិច្ចសហការបានយ៉ាងល្អប្រកបដោយជំហរអព្យាក្រិត្យ រួមចំណែកយ៉ាងសកម្មក្នុងការធ្វើឱ្យសំរេចនៅការរៀបចំការបោះឆ្នោតនៅខេត្តក្រចេះទទួលបានជោគជ័យជាបន្តបន្ទាប់ និងសូមថ្លែងអំណរគុណដល់តំណាងគណបក្សនយោបាយទាំងអស់ ដែលតែងតែចូលរួមសហការអភិវឌ្ឍន៍ការរៀបចំបោះឆ្នោតប្រកបដោយសុឆន្ទៈ

ទោះបីអស់លោកមានឆន្ទៈនយោបាយផ្សេងគ្នាក៏ពិតមែន ប៉ុន្តែអ្វីដែលអស់លោកមានដូចគ្នា គឺឧត្តមគតិជាតិដ៏ខ្ពង់ខ្ពស់ ។ ជោគជ័យនៃការរៀបចំបោះឆ្នោតកន្លងមកគឺមិនអាចកាត់ផ្តាច់បានពីការរួមចំណែកដ៏ធំធេងរបស់អ្នកទាំងអស់ដែរ ។

**លោក ឱក សេរី សោភក្តិ៍** បានថ្លែងអំណរគុណដល់លោក ស៊ីយឿន ដែលបានលើកឡើងនូវចំណុចវិជ្ជមាន ហើយលោកទុកឱ្យអង្គប្រជុំលើកនៅចំណុចអវិជ្ជមាន ។ អង្គប្រជុំដឹងហើយថាយន្តការបោះឆ្នោតនៅប្រទេសកម្ពុជា ពីយន្តការបោះឆ្នោតមួយទៅមួយការជឿនលឿនមានច្រើនណាស់គ្រប់វិស័យទាំងអស់ ។ លោកសូមឱ្យអង្គប្រជុំលើកចំណុចណាដែលនៅខេត្តក្រចេះនៅមានបញ្ហានៅលើគ្រប់ដំណាក់កាលទាំងអស់ ។

## ០៤.មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការព្រួយបារម្ភពីយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តក្រចេះ

**លោកស្រី ឡាច គីមអី** ក្រុមប្រឹក្សាឃុំគណបក្សសមរង្ស៊ី ឃុំជ្រោយបន្ទាល បានមានចំណាប់អារម្មណ៍លើមូលដ្ឋានរបស់លោកស្រី ដែលកន្លងមកយើងមានប័ណ្ណបោះឆ្នោត ដល់បោះឆ្នោតនៅអាណត្តិនេះយើងអាចដូរពីប័ណ្ណបោះឆ្នោតមកអត្តសញ្ញាណប័ណ្ណ ។ លោកស្រីបានចុះផ្ទាល់ឃើញថាប្រជាពលរដ្ឋមួយចំនួនធំគាត់មិនបានចាប់អារម្មណ៍លើអត្តសញ្ញាណប័ណ្ណទេ គឺមានតែខ្លះៗប៉ុណ្ណោះដែលគេចាប់អារម្មណ៍លើអត្តសញ្ញាប័ណ្ណនេះ ចំណែកប្រជាពលរដ្ឋនៅជនបទចុងកាត់មាត់ញូបគាត់មិនចាប់អារម្មណ៍លើអ្វីទាំងអស់ គាត់ចាប់អារម្មណ៍លើការខ្វះខាតធ្វើយ៉ាងណាឱ្យតែកូនចៅមានហូបចុកគ្រប់គ្រាន់ ។ បញ្ហានេះមានពាក់ព័ន្ធលើការចុះឈ្មោះបោះឆ្នោត យើងបានធ្វើសកម្មភាពមួយចំនួនដើម្បីជួយដល់ គជប គឺយកប័ណ្ណបោះឆ្នោតចាស់ និងរូបថតមួយសន្លឹកយកមកឱ្យ គជប លោកស្រីមានការព្រួយបារម្ភថាពេលបោះឆ្នោតតើប្រជាពលរដ្ឋនោះមានលទ្ធភាព ដើម្បីទៅថតរូបបានដែលឬអត់ តើអង្គប្រជុំមានយុទ្ធវិធីយ៉ាងណាដើម្បីដោះស្រាយរឿងនេះ ។ នៅក្នុងឃុំមួយៗមានគណបក្សដល់ទៅ ៣ ហើយគណបក្សទាំងនោះចាំមើលគ្នា ផ្ទុយទៅវិញនៅពេលគៀកការបោះឆ្នោតលោកស្រីគិតថាយើងនឹងខាតសន្លឹកឆ្នោតដោយសារប្រជាពលរដ្ឋមិនបានចាប់អារម្មណ៍ ។

ដោយមានប្រជាពលរដ្ឋខ្លះបានថតរូបធ្វើអត្តសញ្ញាណប័ណ្ណពីមុនមកហើយតែមិនទាន់បាន គឺបានតែអ្នកថតថ្មី លោកស្រីបានមានសំណូមពរទៅខាងស្នងការថា យើងគួរធ្វើយ៉ាងណាដើម្បីឱ្យការងារនេះងាយស្រួលទាំងអស់គ្នា ។

**លោក រស់ សារ៉េត** មេបញ្ជាការរង ស្នងការដ្ឋាននគរបាលខេត្ត បានជំរាបជូនពីបញ្ហាការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងរយៈកាលកន្លងមកនេះដោយគិតលទ្ធផលត្រឹមថ្ងៃ ១០ ខែវិច្ឆិកា ។ ប្រជាពលរដ្ឋនៅខេត្តក្រចេះដែលបានចុះបញ្ជីគ្រប់គ្រងត្រឹមអាយុ ១៨ ឆ្នាំឡើងត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរសរុបមានចំនួន ១៥៦ ៤៤១ នាក់ យើងបានដំណើរការចែកអត្តសញ្ញាណប័ណ្ណចាប់តាំងពីថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០០ មកដល់ថ្ងៃ ១០ ខែវិច្ឆិកា ឆ្នាំ ២០០៦នេះមាន ២ដំណាក់កាលយើងបានបំពេញបែបបទរួចហើយគឺមានចំនួន ១៤៥ ៦៣៤ នាក់ ក្នុងនោះយើងបានបញ្ជូនឱ្យទៅក្រុមហ៊ុនផលិតសន្លឹកអត្តសញ្ញាណប័ណ្ណសរុបបានចំនួន ១៤២ ២៦៦ សន្លឹក ហើយចំនួនអត្តសញ្ញាណប័ណ្ណដែលក្រុមហ៊ុនបានផលិតជូនមកឱ្យវិញបានចំនួន ១៣១ ២៣៨ សន្លឹក ដែលចំនួនទាំងអស់នេះយើងបានដាក់ជូនទៅឯកឧត្តមអភិបាលខេត្តចុះហត្ថលេខាជាបន្តបន្ទាប់ ប៉ុន្តែមិនទាន់បានបញ្ជូនឱ្យប្រជាពលរដ្ឋទាំងអស់នៅឡើយទេ ។ ទិន្នន័យដែលនៅសល់គិតត្រឹមថ្ងៃ ១០ ខែវិច្ឆិកានេះមានចំនួន ៦ ៨០២ នាក់នៅសល់ចំនួន ៣ស្រុក គឺស្រុកក្រចេះ ស្រុកស្នួល និងស្រុកសំបូរ ចំណែកស្រុកព្រែកប្រសព្វ និងស្រុកឆ្លូង យើងបានបញ្ចប់ហើយ ។ ចំនួននេះមានការលំបាកព្រោះក្រុមហ៊ុនផលិតមានការរអាក់រអួលឃើត ជាក់ស្តែងថ្មីៗនេះទិន្នន័យ ២៨០០ ជាងដែលដាក់ឱ្យ ហើយក្រុមហ៊ុនបានធ្វើឆេះអស់រលីង ហើយយើងចាប់ផ្តើមធ្វើសារថ្មីឡើងវិញនៅស្រុកសំបូរ ។ ដំណាក់កាលដែលធ្វើនេះនិងបញ្ចប់នៅចុងខែធ្នូ ឆ្នាំ២០០៦ ។

ឆ្លៀតក្នុងឱកាសនេះសូមសំណូមពរដល់អាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំសង្កាត់ជួយជំរុញប្រជាពលរដ្ឋទាំងអស់ឱ្យគាត់មកធ្វើអត្តសញ្ញាណប័ណ្ណ ខាងលោកមិនអាចចុះទៅធ្វើតាមផ្ទះបានទេ ព្រោះមិនអាចយកម៉ាស៊ីនទៅបាន ។

ឆ្លើយតបទៅនិងបញ្ហារបស់លោកស្រីគីមអី លោកនឹងសិក្សាលើបញ្ហានេះម្តងទៀត ហើយសូមប្រាប់ថាឈ្មោះអី ដើម្បីឱ្យខាងជំនាញគេស្រាវជ្រាវមើល ព្រោះកន្លងមកក្រោយពីចុះហត្ថលេខាអភិបាលខេត្តរួចគេប្រគល់ឱ្យខាងស្រុក ហើយស្រុកប្រគល់ឱ្យឃុំជាអ្នកផ្តល់ជូន ។

**លោក ឱក សេរី សោភក្តិ** បានមានប្រសាសន៍តួលេខដែលលោកស្នងការបានជម្រាបមកនេះ បើប្រៀបធៀបទៅនិងខេត្តផ្សេងទៀតគឺខេត្តក្រចេះធ្វើបានច្រើនណាស់ ។ នៅខេត្តឯទៀតនៅពេលដែលយន្តការខប់សែលលើកបញ្ហាឡើង គ្រប់គណបក្សនយោបាយសង្គមស៊ីវិលដែលលោកដឹងច្បាស់ថានៅភូមិ ឃុំ ឈ្មោះនេះអ្នកដែលបានធ្វើអត្តសញ្ញាណប័ណ្ណមួយហើយនៅមិនទាន់បាន គាត់លើករឿងនេះប្រាប់ទៅស្នងការនៅក្នុងអង្គប្រជុំ ប៉ុន្មានសប្តាហ៍ក្រោយមកយើងដឹងថាខាងស្នងការគេដោះស្រាយឱ្យបាន ដូច្នេះសូមឱ្យយើងប្រើយន្តការខប់សែលនេះដើម្បីលើកយកបញ្ហាអ្វីដែលយើងមានយកមកបង្ហាញនៅក្នុងអង្គប្រជុំ គឺមានប្រសិទ្ធិភាពណាស់ ប៉ុន្តែសូមឱ្យច្បាស់ពីឈ្មោះ ទីតាំង ។ លោកបានជំរាបជូនអង្គប្រជុំថាកំលាំងយន្តការខប់សែលគឺនៅលើរបាយការណ៏ កំណត់ហេតុ អញ្ចឹងបានជាអង្គប្រជុំមានប្រសាសន៏គឺថតសម្លេងយកទាំងអស់ ហើយពេលដែលកំណត់ហេតុចេញមកមិនមានការដូរទេ យើងគ្រាន់តែសំរួលភាសាសំដីឱ្យទៅជាភាសាសរសេរ ។ ហើយកំណត់ហេតុនេះគឺផ្ញើរថ្វាយទៅព្រះមហាក្សត្រ ជូនទៅសម្តេចប្រធានព្រឹទ្ធសភា សម្តេចប្រធានរដ្ឋសភា សម្តេចនាយករដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ព្រមទាំងជូនទៅខាងចៅហ្វាយខេត្ត អភិបាល អភិបាល រងខេត្តរហូតដល់ស្រុកទាំងអស់ ។

**លោក រស់ សារ៉េត** បានបន្ថែមលើបញ្ហាអត្តសញ្ញាណប័ណ្ណ គឺជំហ៊ានទី១ ដែលផ្តល់ជូនប្រជាពលរដ្ឋមួយសន្លឹកតំលៃ ៥ដុល្លា គឺរាជរដ្ឋាភិបាលជាអ្នកចេញ ប៉ុន្តែបើផ្តល់ជូនឱ្យគាត់ហើយគាត់ធ្វើបាត់ហើយទៅផលិតជាលើកទី២ គឺយើងត្រូវចំណាយ៥ដុល្លា ឱ្យក្រុមហ៊ុនដោយខ្លួនឯង ។

**លោក ហ៊ុំ សាគន្ធ** នាយកសំរបសំរួលអង្គការអភិវឌ្ឍន៏សហគមន៏កម្ពុជា (CCD) បានមានចំណាប់អារម្មណ៏គាំទ្រទៅនិងមតិរបស់លោកស្នងការដែលនិយាយពីអត្តសញ្ញាណប័ណ្ណសំរាប់ប្រជាពលរដ្ឋ លោកផ្ទាល់ទទួលធ្វើអត្តសញ្ញាណប័ណ្ណ ប៉ុន្តែនៅពេលដំណើរការលើកទី១ចេញដំណើរយើងចាប់ផ្តើមទៅយក ឃើញថាទី១ គេស្នើសុំថវិការដើម្បីទៅរកអត្តសញ្ញាណប័ណ្ណ ទី២ ថវិការបង់រួចហើយប៉ុន្តែរកមិនឃើញ ។ ករណីប្រជាពលរដ្ឋធ្វើបាត់ដោយខ្លួនឯង ហើយពេលធ្វើម្តងទៀតត្រូវបង់លុយ ៥ដុល្លា លោកសូមសួរថាចុះបើករណីភ្នាក់ងាររបស់រដ្ឋជាអ្នកធ្វើបាត់ តើអ្នកណាជាអ្នកបង់លុយ ។ ហើយការធ្វើម្តងទៀតតើអ្នកណាជាអ្នកជួយចេញខាតឱ្យប្រជាពលរដ្ឋ ។

**លោក រស់ សារ៉េត** បានបកស្រាយលើបញ្ហានេះថា បើពិនិត្យលើម៉ាស៊ីនកុំព្យូទ័រឃើញថាបាត់នៅលើក្រុមហ៊ុន គឺក្រុមហ៊ុនជាអ្នកធ្វើសង តែបើបាត់លើយើងខ្លួនឯង គឺម្ចាស់ខ្លួនជាអ្នកចេញលុយ ។

**លោក ស៊ីវិត វណ្ណា** មន្ត្រីអាជហុកខេត្តក្រចេះ ទាក់ទងនិងការសង្កេតការចុះឈ្មោះបោះឆ្នោតចំពោះស្រុកទាំង ៥ មានវិជ្ជមាន និងអវិជ្ជមាន ។ ចំណុចអវិជ្ជមានទី១ ត្រង់ប្រជាពលរដ្ឋមានការចំណាកស្រុក ទី២ គាត់មិនអាចចាប់អារម្មណ៏ពីបញ្ហានេះទេ គឺគាត់ចាប់អារម្មណ៏តែបញ្ហាជីវភាពរបស់គាត់ តែទោះជាយ៉ាងណាក៏ដោយក៏គាត់នៅតែព្យាយាមបន្ត ។ លោកបានមានសំណូមពរទៅក្រុមប្រឹក្សា

ឃុំទាំងអស់ និងលោកអភិបាលស្រុកជាកងឯកភាពស្រុក ធ្វើយ៉ាងណាទប់ស្កាត់ឱ្យបាននៅអាវុធ ដោយសព្វថ្ងៃនេះមានអាវុធសំបូរពេក នៅតាមបណ្តាឃុំ ជាពិសេសនៅឃុំស្នួល ឃុំផ្សីម គឺមានបញ្ហា ។

**លោក អ៊ុំ ណារិទ្ធិ** តំណាងគណបក្សសម រង្ស៊ី មកពីស្រុកស្នួល បានចាប់អារម្មណ៍លើសំដីលោក សោភក្តិ ត្រង់ចំណុចថាចង់ឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះដោយខ្លួនឯងឱ្យបានច្រើន លោកគិតថាប្រជាពលរដ្ឋលោកមិនមែនរាំងស្ទះមិនចង់ទៅចុះឈ្មោះបោះឆ្នោតទេ ប៉ុន្តែយើងឃើញថា គជប ថ្មី១នេះដាក់វិធានការស្មុគ្រស្មាញពេក គឺរឿងរូបថត ។ កន្លងមកយើងថាបោះឆ្នោតដោយសេរី និងសំងាត់ ប៉ុន្តែដល់ពេលយើងឱ្យប្រជាពលរដ្ឋមានកាតព្វកិច្ចទទួលខុសត្រូវលើរូបថតគាត់ ហើយគាត់មានការខ្វះខាតនាំឱ្យគាត់មានការរេរាចំពោះបញ្ហានេះ ។ មានគណបក្សនយោបាយរៀងខ្លួនដើម្បីជួយសំរួលដល់ប្រជាពលរដ្ឋ អញ្ចឹងដូចជាជំរុញឱ្យប្រជាពលរដ្ឋបញ្ចេញសកម្មភាពថាគាត់គាំទ្រគណបក្សនយោបាយណាមួយបាត់ហើយ តើយើងថាសំងាត់ដោយរបៀបយ៉ាងម៉េច? ។ គេឆ្លើយថាប្រជាពលរដ្ឋនៅពេលទៅបោះឆ្នោតគឺគូសដោយសំងាត់ ប៉ុន្តែលោកបានសង្កេតឃើញគណបក្សនយោបាយខ្លះបានប្រើពាក្យថា បើសិនជនណាចង់គូសត្រូវគណបក្សណា ចូលថតខាងគណបក្សនោះ ។ ដល់អញ្ចឹងប្រជាពលរដ្ឋខ្លះមិនហ៊ានចេញមុខផ្ទាល់ទេ គាត់មានការរុញរា នាំឱ្យមានការអាក់ខាន ។

ចំពោះបញ្ហាអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋនៅស្រុកស្នួលមានការចាប់អារម្មណ៍ណាស់ពីបញ្ហានេះ លោកក៏មានការឯកភាពលើប្រសាសន៍របស់លោកស្នងការរងដែលថាស្នងការបានចុះទៅធ្វើអត្តសញ្ញាណប័ណ្ណនៅស្រុកស្នួល ប៉ុន្តែមានការខ្វះខាតដូចជាបាត់ ។ មានប្រជាពលរដ្ឋខ្លះមកសួរលោកថា គាត់ធ្វើអត្តសញ្ញាណប័ណ្ណចំនួន ៥ឆ្នាំ ៣ឆ្នាំ ១ឆ្នាំ ហើយនៅមិនទាន់បានទទួលនៅឡើយទេ ដល់គាត់ទៅសុំធ្វើថ្មីខាងប៉ូលិសមិនឱ្យធ្វើ មិនដឹងជាមកពីមូលហេតុអ្វី ។

ចំណុចមួយទៀតមានប្រជាពលរដ្ឋមួយគ្រួសារនៅក្នុងឃុំស្នួល គាត់មានអត្រានុកូលដ្ឋានបញ្ជាក់ពីកំណើត សញ្ជាតិរួចហើយ យើងទទួលស្គាល់គាត់ថាជាជនជាតិខ្មែរ ប៉ុន្តែដល់ពេលគាត់ទៅធ្វើអត្តសញ្ញាណប័ណ្ណអាជ្ញាធរប៉ូលីសបដិសេធមិនព្រមធ្វើអត្តសញ្ញាណប័ណ្ណជូនគាត់ទេ ដោយខាងប៉ូលីសទាមទារថាឱ្យធ្វើលិខិតផ្លាស់ប្តូរទីលំនៅ ។ ប្រជាពលរដ្ឋខ្មែរសព្វថ្ងៃខ្វះខាតច្រើនណាស់ ការចំណាកស្រុកនៅមានបញ្ហាច្រើន ហើយគាត់មិនសូវចាប់អារម្មណ៍លើបញ្ហាផ្លាស់ទីលំនៅនេះទេ ជាពិសេសត្រូវការលុយកាក់សំរាប់ឱ្យភូមិ ឃុំ ក្នុងការចុះហត្ថលេខា នាំឱ្យគាត់មិនរវល់រឿងលិខិតបញ្ជាក់ការផ្លាស់ប្តូរទីលំនៅ ។

ចំពោះចំណុចដែលថាក្រោយបោះឆ្នោតកុំឱ្យជាប់គាំង បើយើងមើលសកម្មភាពកន្លងមកបញ្ហានយោបាយនៅស្រុកខ្មែរ យើងនិយាយថាអព្យាក្រឹត្យ ជាពិសេសអាជ្ញាធរអព្យាក្រឹត្យ ។ លោកឃើញថានៅក្នុងឃុំស្នួល ពេលចុះឈ្មោះកន្លងមក គឺឃុំដាក់ផែនការជូនទៅឃុំឱ្យគាត់ជំរាបប្រជាពលរដ្ឋឱ្យមកពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប៉ុន្តែគាត់បែរជាទៅប្រាប់ប្រជាពលរដ្ឋថាឱ្យមកប្រជុំ ដល់ប្រាប់ថាមកប្រជុំគាត់មកមិនមានកាន់ឯកសារអ្វីមកជាមួយទេ ដល់ពេលមកដល់អាជ្ញាធរទាមទាររកឯកសារដើម្បីគាត់ពិនិត្យ អញ្ចឹងគាត់ត្រូវត្រឡប់ទៅវិញ នេះជាបញ្ហាបង្កឱ្យគាត់មានការធុញទ្រាន់ ។ ពេលនោះក៏មានការជជែកគ្នាជាមួយតំណាងគណបក្សសម រង្ស៊ី មានរហូតដល់ប្រធានភូមិប្រើពាក្យអសីលធម៌មកលើតំណាងគណបក្ស ។

នៅឃុំស្រែចារ លោកមានបញ្ហាចង់ជំរាបសួរ គឺនៅការិយាល័យអ្នកកណ្តាល ០២៥៣ ចំនួនចុះឈ្មោះថ្មីដែលលើសពី ៧០០នាក់ នៅក្នុងការិយាល័យ តើយកទៅដាក់នៅកន្លែងណាវិញ? ។ នៅឃុំអញ្ចាញ ០២៥២ អ្នកដែលមានឈ្មោះនៅក្នុងបញ្ជី គជប ស្រាប់ តែមិនទាន់មានអត្តសញ្ញាណប័ណ្ណ តើគាត់អាចធ្វើបន្តនៅឯណាបានទៀត? ។ ចំពោះអ្នកដែលបានចុះឈ្មោះហើយ តែមិនបានបោះត្រាលើរូបថត តើអាចទៅបោះឆ្នោតបានទេ? ព្រោះតាមសំដីតំណាងប្រធានក្រុមប្រឹក្សាឃុំស្រែចារគណបក្ស សមរង្ស៊ី បានរាយការណ៍ថាគាត់

បានទៅសួរស្មៀនឃុំស្រែចារ ថាតើចាំបាច់បោះត្រាលើរូបថតដែរឬទេ? ស្មៀនឃុំឆ្លើយថាមិនបាច់បោះត្រាទេ គ្រាន់តែបិទរូបថតមួយសន្លឹកហើយដល់ថ្ងៃបោះឆ្នោតកាន់យកទៅបោះបានហើយ ។

**លោក អ៊ុង ស៊ីយឿន** បានសរុបជាសង្ខេបនៅសំណួរដែលអង្គប្រជុំបានលើកឡើង ទី១ ការព្រួយបារម្ភទាក់ទងនិងប្រជាពលរដ្ឋដែលចំណាកស្រុក តើការចុះឈ្មោះគាត់នឹងដំណើរការទៅរបៀបម៉េច ។ ទី២ មានការិយាល័យដែលមានប្រជាពលរដ្ឋលើសចំនួន ៧០០នាក់ ។ ទី៣ នៅឃុំអញ្ចាញដែលមានប្រជាពលរដ្ឋបានចុះឈ្មោះហើយ ប៉ុន្តែមិនដឹងជាយ៉ាងម៉េច ។ ទី៤ ការខកខានមិនបានបោះត្រាលើរូបថតនៃទម្រង់ ១០១៨ ។

**ទី១** ទាក់ទងនិងបញ្ហាចំណាកស្រុក ជានីតិវិធីរបស់ គជប ក៏ដូចជាលេខាធិការដ្ឋានរៀបចំការបោះឆ្នោតយើងមានដំណោះស្រាយមួយជូនដល់ប្រជាពលរដ្ឋ គឺគ្រាន់តែឱ្យគាត់ស្នើសុំនៅលិខិតបញ្ជាក់ពីការផ្លាស់ទីលំនៅតាមទម្រង់ ១០១៩ ចេញដោយមេឃុំហើយគាត់យកទម្រង់នេះទៅបង្ហាញជូនខាងស្មៀនថាគាត់បានផ្លាស់ទីចូលមកនៅក្នុងឃុំសង្កាត់នេះហើយ ។ ស្មៀនអនុវត្តនីតិវិធីបន្តទៀតទាក់ទងនៅនិងអត្តសញ្ញាណ ក៏ដូចជាលិខិតផ្សេងៗជាភាពមានសិទ្ធិដែលអាចចុះឈ្មោះបាន ដូច្នេះដំណើរការចុះឈ្មោះនិងប្រព្រឹត្តិទៅបានល្អហើយ ។ ចំពោះបញ្ហាព្រួយបារម្ភរបស់លោកស្រីដែលបានលើកឡើងថា មានការព្រួយបារម្ភចំពោះប្រជាពលរដ្ឋដែលមិនសូវគិតគូរទាក់ទងនិងការសុំឯកសារនេះ ជាគោលការណ៍ គជប បានផ្តល់ព័ត៌មានជាបន្តបន្ទាប់រហូតដល់ផលិតប័ណ្ណព័ត៌មានសំរាប់មនុស្សម្នាក់ មានពតិមានខ្លួនគាត់ម្នាក់ ។

**ទី២** ការិយាល័យដែលមានប្រជាពលរដ្ឋលើសចំនួន ៧០០នាក់ តាមការដែលលោកសង្កេតនៅក្នុងរបាយការណ៍ជាគោលការណ៍ការរៀបចំការបោះឆ្នោត ឯកសារមានភាពសុក្រិតណាស់ មិនអាចគ្រាន់តែសរសេររបាយការណ៍១-២សន្លឹក យកជាបានការទេ ។ នៅក្នុងបច្ចេកទេសនៃការរៀបចំពិនិត្យអំពីទិន្នន័យផ្សេងៗនៅក្នុងឃុំមួយណានោះ គជប តំរូវឱ្យមានឯកសារច្រើនណាស់ ឧទាហរណ៍ការិយាល័យអ្នកកណ្តាលដែលថាមានជាង ៧០០ នាក់ ឥឡូវឧបមាថាលោកពិនិត្យឃុំស្រែចារ តំបូងគឺពិនិត្យលើរបាយការណ៍រួមរបស់គាត់ ដែលហៅថាទម្រង់ ១០១២ ដែលរបាយការណ៍នេះនិយាយពីទិន្នន័យផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោតនីមួយៗ ។ នៅក្នុងរបាយការណ៍ដែលលោកបានទទួលនៅឃុំស្រែចារ គឺមិនមានចំនួនដែលលើសជាង៧០០នាក់នេះទេ លោកបានមើលឯកសារទាំងបញ្ជីឆ្នាំ ២០០៥ ដែលបោះពុម្ពដោយកុំព្យូទ័រ បូកនិងបញ្ជីដែលចុះឈ្មោះថ្មីដែលសរសេរដោយដៃនៅឆ្នាំ ២០០៦ ហើយដកចំនួនដែលគាត់មានលុបខ្លះ ។ រាល់ឯកសារទាំងអស់ត្រូវមានភស្តុតាង ត្រូវចុះហត្ថលេខាដោយគណបក្សនយោបាយលើទម្រង់ ១០១១ អំពីរបាយការណ៍នៅការិយាល័យនីមួយៗ ។

**ទី៣** ទាក់ទងនិងប្រជាពលរដ្ឋដែលបានចុះឈ្មោះហើយបារម្ភថាខ្លាចមិនមានឈ្មោះ ជានីតិវិធីក្រុមប្រឹក្សាឃុំមានចុះហត្ថលេខាលើកំណត់ហេតុរបស់ PEC មួយដែលកំណត់ហេតុធ្វើឡើងដោយក្រុមប្រឹក្សាឃុំផ្ទាល់ ។ ជាបច្ចេកទេសនៅពេលដែលបញ្ចប់ការចុះឈ្មោះនីមួយៗក្រោយរយៈពេល ៤ថ្ងៃយើងរៀបចំបិទផ្សាយបញ្ជីតំបូង ដែលរួមមានបញ្ជីបោះពុម្ពដោយកុំព្យូទ័រក្រោយកែតំរូវ បូកនិងបញ្ជីដែលស្មៀនចុះឈ្មោះថ្មី ហើយមានកំណត់ហេតុមួយទៀតភ្ជាប់ដែលមានចុះហត្ថលេខាដោយក្រុមប្រឹក្សាឃុំទាំងអស់ថាបានបិទផ្សាយបញ្ជី គោលដៅនៃការបិទផ្សាយដើម្បីជំរាបជូនថា តើប្រជាពលរដ្ឋដែលបានមកចុះឈ្មោះហ្នឹង មានឈ្មោះហើយឬនៅ រយៈពេល ៣ថ្ងៃក្រោយលោកអាចឃើញថាតើបាត់ ឬឃើញឈ្មោះ ឬខុស ហើយលោកអាចប្តឹងតវ៉ាបាន ។

**ទី៤** បញ្ហាមិនបានបោះត្រាលើរូបថតនៃទម្រង់ ១០១៨ ជាបច្ចេកទេសរូបថតគឺបញ្ជាក់អត្តសញ្ញាណនៃបុគ្គលម្នាក់ៗ ការដែលបោះត្រាលើរូបថតគឺជាការបំពេញគ្រប់គ្រាន់ទៅលើការងារនីតិវិធី ធ្វើដូច្នេះទើបអាចយកទៅប្រើការបាន ។

**លោក រស់ សារ៉េត** បានឆ្លើយនិងសំណួររបស់តំណាងគណបក្សសមរង្ស៊ី

**ទី១** បញ្ហាអត្តសញ្ញាណប័ណ្ណដែលប្រជាពលរដ្ឋធ្វើហើយ តែគាត់មិនបានទទួល ជាធម្មតាពេលធ្វើអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបានទទួលនៅកន្ទុយប័ណ្ណមួយដែលសមត្ថកិច្ចផ្តល់ជូន លោកបានសំណូមពរថាបើប្រជាពលរដ្ឋណាដែលមានកន្ទុយប័ណ្ណ តែមិនទាន់បានទទួល សូមយកកន្ទុយប័ណ្ណទៅជួបប៉ុស្តិ៍រដ្ឋបាលដែលនៅជិតបំផុត ដើម្បីឱ្យប៉ុស្តិ៍រដ្ឋបាលរាយការណ៍ទៅស្នងការដ្ឋាន ហើយយើងនិងរៀបចំកម្មវិធីណាមួយដែលសមស្របនិងដោះស្រាយជូន ។

**ទី២** បញ្ហាដែលប្រជាជនមានការចំណាកស្រុក បើគ្មានការផ្ទេរលំនៅដ្ឋានច្បាស់លាស់ សមត្ថកិច្ចនគរបាលមិនអាចធ្វើឱ្យបានទេ នេះជាច្បាប់ ទោះបីគាត់មានសញ្ជាតិជាខ្មែរក៏ដោយ ប៉ុន្តែខាងស្នងការដ្ឋានអនុគ្រោះថា បើសិនជាប្រជាជននៅក្នុងខេត្តក្រចេះ ឧទាហរណ៍ ឥឡូវក្រុមការងារស្ថិតិអត្តសញ្ញាណប័ណ្ណកំពុងផ្តល់ឱ្យស្រុកស្នួល ប៉ុន្តែប្រជាពលរដ្ឋនៅស្រុកក្រចេះគាត់ចង់ធ្វើប្រញាប់ គាត់អាចកាន់សៀវភៅ ក៤ ទៅធ្វើនៅស្រុកស្នួលក៏បានដែរ ឱ្យតែប្រជាពលរដ្ឋនៅខេត្តក្រចេះ តែប្រជាពលរដ្ឋនៅក្រៅខេត្តជាផ្លូវច្បាប់លោកមិនហ៊ានទេ។ ចំពោះការផ្ទេរលំនៅដ្ឋានមិនមានការពិបាកទេ គ្រាន់តែចុះហត្ថលេខាពីប៉ុស្តិ៍រដ្ឋបាលហើយឱ្យគេមើលប័ណ្ណ ក៤ ។

**លោក ឱក សេរី សោភក្តិ** មានព័ត៌មានដែលយើងបានទទួលដែលថា នៅស្រុកស្នួល មេភូមិដែលអញ្ជើញប្រជាពលរដ្ឋមកដើម្បីឱ្យធ្វើការចុះឈ្មោះ ប៉ុន្តែលោកប្រាប់ថាឱ្យមកប្រជុំ ដោយសារមិនមានឯកសារអីយកមក នេះជាការដែលខប់សែលចង់បានព័ត៌មានច្បាស់ ព្រោះនៅខេត្តផ្សេងៗទៀតពេលដែលបានព័ត៌មានច្បាស់ ខាង គជប ខាងក្រសួងមហាផ្ទៃក្តី លោកចុះទៅធ្វើការស្រាវជ្រាវថាតើរឿងហ្នឹងពិតប្រាកដដែរទេ ។ អញ្ចឹងបានជាយន្តការខប់សែលជួយតួអង្គទាំងអស់ដែលពាក់ព័ន្ធនិងរឿងបោះឆ្នោត ជួយអាជ្ញាធរដូចជា គជប ក្រសួងមហាផ្ទៃ ដើម្បីឱ្យលោកបានទទួលដំណឹងដែលក្នុងពេលធម្មតាលោកមិនបានទទួលទេ នេះជាការដែលអាចជួយដល់រាជរដ្ឋាភិបាលក្នុងការតាមមើលថា តើការអនុវត្តន៍ផែនការដែលបានដាក់ឱ្យធ្វើបានត្រឹមត្រូវយ៉ាងណា ។

បញ្ហាដែលអង្គប្រជុំបានស្តាប់ គឺមានបញ្ហាចុះឈ្មោះបោះឆ្នោត បញ្ហាការិយាល័យបោះឆ្នោត និងបញ្ហាអត្តសញ្ញាណប័ណ្ណ នេះជាការកង្វល់ហើយ ក៏ជាបញ្ហាដែលយើងប្រឈមនៅក្នុង ខេត្តក្រចេះ ។ ទាក់ទងនិងរឿងនេះដែរ គឺអាកប្បកិរិយារបស់ប្រជាពលរដ្ឋដែលមិនសូវយកចិត្តទុកដាក់ក្នុងរឿងក្រដាសស្នាម បើសិនជាយើងមើលលទ្ធផលហើយអ្វីដែលយើងចង់បាន គឺយើងគិតថាមានការមិនយកចិត្តទុកដាក់ដូចខេត្តឯទៀតៗដែរ ប៉ុន្តែបើយើងគិតមើលថាប្រទេសយើងទើបតែចេញពីសង្គ្រាម ហើយយើងអាចកែទម្លាប់របស់ គាត់ក្នុងចំណោម ១៥៦ពាន់នាក់ មាននៅសល់ប្រហែល ៦-៧ពាន់នាក់តែប៉ុណ្ណោះ ។ លោកបានឯកភាពជាមួយនិងវាគ្មិនដែលបានលើកឡើង ប៉ុន្តែសង្កេតឃើញថាការអប់រំប្រជាពលរដ្ឋ ដែលយើងហៅថា voter និង civil education ដែល UNDP បានយកចិត្តទុកដាក់នៅក្នុងរឿងហ្នឹង តោងតែអង្គការសង្គមស៊ីវិល គណបក្សនយោបាយរួមគ្នាធ្វើការជាមួយនិងអាជ្ញាធរមូលដ្ឋាន ដើម្បីបន្តអប់រំដល់ប្រជាពលរដ្ឋឱ្យយល់ពីសារៈសំខាន់នៃសន្លឹកអត្តសញ្ញាណប័ណ្ណ ការទៅថតរូបដើម្បីបានបំពេញលើកម្រេង ១០១៨ ។ លោកឯកភាពជាមួយមតិដែលលើកឡើងថាបើសិនគណបក្សនយោបាយជាអ្នកផ្តល់រូបថតនេះក៏ដូចជាការទិញទឹកចិត្តមួយដែរ ។

លោកសង្ឃឹមថាបញ្ហាទាំងអស់នេះយើងនឹងបន្តរួមគ្នា ធ្វើការអប់រំលើកដាក់កម្មវិធីផ្សព្វផ្សាយតាមរយៈការអប់រំផ្ទាល់នៅតាមមូលដ្ឋាន ការអប់រំតាមវិទ្យុ ទូរទស្សន៍ កាសែត តាមការប្រជុំ សិក្ខាសាលា សន្និសីទក្តី ដើម្បីឱ្យប្រជាពលរដ្ឋយល់នូវសារៈប្រយោជន៍នៃលិខិតជាផ្លូវការ អត្រានុកូលដ្ឋាន អត្តសញ្ញាណប័ណ្ណ ដើម្បីចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ។ បើសិនជាយើងធ្វើរួមគ្នាបែបនេះយ៉ាងយូរ ៥ឆ្នាំទៀតនិងក្លាយទៅជាទម្លាប់ធម្មតារបស់ប្រជាពលរដ្ឋ ។

**លោក សូត្រ សុផល** អនុប្រធានប្រតិបត្តិខេត្ត តំណាងគណបក្ស ហ៊្វុនស៊ិនប៉ិច ខេត្តក្រចេះ ពាក់ព័ន្ធនិងការបោះឆ្នោតដែលនឹងប្រព្រឹត្តទៅនៅពេលខាងមុខការអនុវត្តន៍កន្លងមក ដែលលោកបានជួបប្រទេះពាក់ព័ន្ធបញ្ហាពីដំណាក់កាលមួយទៅដំណាក់កាលមួយ ។

**ទី១** លោកសង្កេតឃើញថា គជប ចេញនីតិវិធីមកចេះតែមានបញ្ហាស្មុគ្រស្មាញទៅៗ ជាពិសេសរឿងទម្រង់ ១០១៨ ។ ទម្រង់ ១០១៨ សំរាប់ប្រជាពលរដ្ឋដែលមិនមានអត្តសញ្ញាណប័ណ្ណ ហើយគាត់ត្រូវការបំពេញទម្រង់នេះ តែគាត់គ្មានរូបថត នាំឱ្យគាត់មានបញ្ហាគឺគ្មានលុយទៅថតរូបសំរាប់បិទទម្រង់ ១០១៨ ។ ដល់ពេលសួរទៅ គជប ថាឱ្យប្រជាពលរដ្ឋថតខ្លួនឯងទៅ លោកឆ្ងល់ថា គជប ទទួលប្រាក់ខែពីប្រជាពលរដ្ឋ និងជាតិ ហេតុអ្វីក៏ដាក់បន្ទុកកាន់តែធ្ងន់ទៅលើប្រជាពលរដ្ឋវិញ ។

**ទី២** រឿងប័ណ្ណព័តិមាន កន្លងមកការផ្សព្វផ្សាយប័ណ្ណព័តិមានគឺមិនមានតម្លាភាព ។ គណបក្សដែលមានអំណាច មានលទ្ធភាពគេអាចផ្សព្វផ្សាយជូនទៅសមាជិកគេទូលំទូលាយ ប៉ុន្តែចំពោះគណបក្សដែលទន់ខ្សោយនាំឱ្យមិនមានតួនាទីជាមេភូមិ ដើម្បីយកប័ណ្ណព័តិមានទៅចែក នាំឱ្យព័តិមានទទួលបានដោយកន្លែង ។ ដល់ពេលកំណត់ដែលត្រូវរាយការណ៍ថាបានប៉ុន្មាន ប័ណ្ណព័តិមាននៅច្រើន នាំឱ្យត្រូវពន្យាចែកតទៅទៀត ជាក់ស្តែងលោកផ្ទាល់រស់នៅឃុំក្រចេះ ភូមិវត្ត ប័ណ្ណព័តិមានមិនទាន់បានមកដល់លោកទេ ប៉ុន្តែផុតថ្ងៃដែលគេកំណត់ ហើយមានការពន្យាពេលទៀត ហើយមេឃុំគេជំរុញថាចែកបន្តទៀតទើបប័ណ្ណនេះបានមកដល់លោក នេះដោយសារការរើសអើងនយោបាយ ។ អញ្ចឹងការផ្សព្វផ្សាយនេះមានបញ្ហាស្មុគ្រស្មាញ ហើយក្រុមប្រឹក្សាឃុំពាក់ព័ន្ធនិងរឿងថវិការ ដល់ថវិការស្តួចស្តើងការផ្សព្វផ្សាយមិនបានទូលំទូលាយ ។

ពាក់ព័ន្ធរឿងនីតិវិធីដែលហៅស្មៀន ក្រុមប្រឹក្សាឃុំឱ្យមករៀន អ្នកខ្លះត្រងត្រាប់ចង់ចេះចង់យល់ ដល់ពេលប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតនាំឱ្យមានភាពងាយស្រួល ប៉ុន្តែដល់អ្នកខ្លះដែលគាត់មិនចង់ចេះ គាត់បង្កបញ្ហាស្មុគ្រស្មាញដល់ប្រជាពលរដ្ឋ ។ ដោយប្រជាពលរដ្ឋគាត់ខ្វល់ពីបញ្ហាខ្វះខាត គាត់ថាបើពិបាកយ៉ាងហ្នឹងមិនបាច់បោះឆ្នោតក៏បានដែរ ។ ដល់យើងជំរុញថាគ្រប់គណបក្សនយោបាយទាំងអស់ត្រូវតែជួយជំរុញក្នុងការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋមកចុះឈ្មោះឱ្យបានច្រើន ប៉ុន្តែបើយើងនិយាយពីកាតព្វកិច្ចរបស់ គជប បង្កើតអាជ្ញាធរនេះមកដើម្បីរឿងការបោះឆ្នោត អញ្ចឹងគាត់ត្រូវតែធ្វើការងារហ្នឹង គាត់មិនត្រូវផ្តេកផ្តួលទៅលើគណបក្សនយោបាយពេកទេ ។

ចំពោះបញ្ហាសន្តិសុខលំបាកដោយសារប៉ូលីស ទាហ៊ាន ចេញមកពីកូតាគណបក្ស ដល់ពេលគណបក្សផ្សេងរងគ្រោះ ហើយខ្លួនឯងចំកន្លែងមានអំណាចគេដោះស្រាយទំនាស់នោះ ធម្មតាបើនៅក្នុងក្រុមតែមួយត្រូវតែធ្វើមិនដឹងមិនឮ តែចំពោះគេអ្នកក្រៅបើខុសហើយគឺរិតតែម្តង ។ កន្លងមកស្ថាប័នកងកម្លាំងប្រដាប់អាវុធមិនទាន់ទៅជាស្ថាប័នឯករាជ្យ អព្យាក្រឹត្យ នៅចំណុះឱ្យគណបក្សនយោបាយ នេះហើយជាបញ្ហារងគ្រោះដល់គណបក្សទន់ខ្សោយ ។

រឿងចុះឈ្មោះ ជាក់ស្តែងនៅក្នុងឃុំ ច្រឡំតាមដែលលោកពិនិត្យមើលប័ណ្ណព័តិមានដែលចែកទៅ ហេតុអីក៏ខុសនិងបញ្ជីឈ្មោះទៀត នេះមានការខុសច្រើនណាស់ ។ ជាក់ស្តែងរូបលោកផ្ទាល់នៅក្នុងភូមិក្រចេះលោកបាត់ថ្ងៃ ខែ ឆ្នាំ ហើយបានទៅឱ្យស្មៀនកែ ដល់ស្មៀនគាត់ថាមិនបាច់កែទេបោះឆ្នោតទាំងអញ្ចឹងទៅ តែលោកបានទាមទារឱ្យកែឱ្យដូចអត្តសញ្ញាណប័ណ្ណ នេះស្មៀនមិនចង់កែឱ្យលោកផងចុះទម្រាំតែអ្នកដែលមិនយល់ពីនីតិវិធី តើបញ្ហានេះនឹងកើតឡើងយ៉ាងម៉េចទៀត ដោយសារក្រុមប្រឹក្សាឃុំឃើញលោកជាតំណាងគណបក្សមួយដែរក៏ជំរុញថាត្រូវតែកែឱ្យលោក ។

ចំពោះនីតិវិធីចុះឈ្មោះ ឃើញថាឈ្មោះនៅក្នុងបញ្ជីចុះឈ្មោះបោះឆ្នោតផ្សេង ហើយនៅក្នុងអត្តសញ្ញាប័ណ្ណផ្សេង ដល់ពេលគាត់ទៅគាត់យកអត្តសញ្ញាណប័ណ្ណទៅចុះតែម្តង នាំឱ្យលទ្ធផលបច្ចុប្បន្ន បើធ្វើការដកតួរលេខបញ្ជីបច្ចុប្បន្នភាពឆ្នាំ ២០០៥ និងស្ថិតិឆ្នាំ

២០០៦ វានៅសល់អ្នកមិនទាន់ចុះឈ្មោះតែ ១៧ ០០០ នាក់ជាង ឥឡូវដល់ចុះកើនដល់ ១៩ ០០០នាក់ជាង លោកគិតថាតួរលេខនេះមិនទាន់សុក្រឹត្យ ព្រោះឆ្នាំ ២០០៥ ចុះបានតែ ២០ ៥៨០នាក់ ដល់ជិតបោះឆ្នោតទៅ ១៩ ០០០ នាក់ជាង ហេតុអីបានជាគំលាតគ្នាឆ្ងាយម្ល៉េះ ។ តាមដែលលោកដឹងប្រហែលជាអ្នកដែលមានឈ្មោះខុសគ្នានៅក្នុងបញ្ជីបោះឆ្នោត និងក្នុងអត្តសញ្ញាណប័ណ្ណ ហើយគាត់ចុះឈ្មោះថ្មី នាំឱ្យលោកសន្និដ្ឋានថាជាឈ្មោះស្ទួន ។

**លោក ឱក សេរី សោភក្តិ៍** បានជំរាបជូនអង្គប្រជុំថានៅថ្នាក់ជាតិដែលយើងបានប្រជុំខប់សែលកាលពីខែមុន ពេលដែលសរុបបញ្ជីអ្នកដែលចុះឈ្មោះថ្មីមានប្រហែល ៦សែននាក់ដែល គជប រៀបចំសំរាប់ធ្វើ ប៉ុន្តែដល់ចុះមែនទែនបានជិតដល់ ១លាននាក់ នាំឱ្យគ្រប់គ្នាមិនយល់ថាហេតុអ្វីព័ត៌មានដែលអាជ្ញាធរមូលដ្ឋាន ជាពិសេសអាជ្ញាធរក្រុមប្រឹក្សាឃុំសង្កាត់ឱ្យទៅ គជប ខុសគ្នាខ្លាំងម្ល៉េះ ។ យើងក៏បានជំរាបទៅក្រសួងមហាផ្ទៃថា បើតួរលេខខុសយ៉ាងហ្នឹងយើងមិនដឹងជាធ្វើយ៉ាងណាដើម្បីត្រួតត្រា គ្រប់បញ្ហាអស់នេះបានទេ មិនដឹងថាតើឈ្មោះស្ទួនច្រើនពេក ឬអ្នកដែលចំណាកស្រុក ប៉ុន្តែបញ្ហានេះត្រូវតែសើរើមកវិញឱ្យទាល់តែបាន ។ ខាង NDI បានជួយបោះទម្រង់ ១០១៨ ដើម្បីជួយចែក គជប ដោយចែកផ្ទាល់រហូតដល់ ៥ម៉ឺនសន្លឹកជាង ដើម្បីបំពេញសេចក្តីត្រូវការរបស់ក្រុមប្រឹក្សាឃុំសង្កាត់ជូនដល់ប្រជាពលរដ្ឋដែលមិនមានអត្តសញ្ញាណប័ណ្ណ ។ ចំពោះលោកប្រធានលេខាធិការដែលបានមានប្រសាសន៏ថាទម្រង់ ១០១៨ នៅពេលដែលបិទរូបថតទាល់តែវាយត្រា ធ្វើនេះត្រឹមត្រូវហើយលោកឯកភាព ប៉ុន្តែតោងតែមើលនីតិវិធីឡើងវិញថា តើត្រូវវាយត្រាគ្រប់កន្លែងមែនឬអត់ ព្រោះខេត្តខ្លះដែលខប់សែលបានទៅដល់ថាបើមិនមានរូបថតគឺមិនបាន ដល់ទៅតវ៉ាជាមួយឯកឧត្តមទេព នីថា បានសុខចិត្តថាឱ្យជឿរូបថតសិន អាចចុះបានឱ្យតែមានឯកសារបញ្ជាក់ ហើយមានសាក្សី២នាក់ ដល់ពេលបោះឆ្នោតចាំរករូបថតមកយើងបិទរូបថតនៅលើទម្រង់ ១០១៨ ។ ឥឡូវបិទរូបថតហើយថាមានវាយត្រាសំគាល់ជាផ្លូវការទៀត ដូច្នេះលោកនឹងលើកបញ្ហានេះនៅខប់សែលថ្នាក់ជាតិ ។

**លោក អ៊ុំ ណារិទ្ធ** បានបញ្ជាក់ថានៅភូមិអ្នកកណ្តាលចំនួន ៧០០នាក់ជាឈ្មោះចាស់ លោកចង់ដឹងថាឈ្មោះថ្មីដែលមានកំនើនរយៈពេល៥ឆ្នាំ លោកឃើញថាខាងឃុំបានចុះទៅតែវាបាត់ឈ្មោះថ្មីមិនដឹងជាយកទៅដាក់នៅកន្លែងណា ។ ចំពោះប័ណ្ណផ្តល់ព័ត៌មានដែលថានៅក្នុងលោកប្រហែលជាគ្មាន ប្រសាសន៏នេះប្រហែលជាត្រូវ ប៉ុន្តែវាក៏អាចបង្កជាបញ្ហាធំបានដែរ បញ្ហាផ្តល់ប័ណ្ណព័ត៌មាននាំឱ្យប្រជាពលរដ្ឋមានការយល់ច្រឡំច្រើនណាស់ សូម្បីតែមនុស្សនៅក្នុងទីផ្សារក៏មានការយល់ច្រឡំដែរ គាត់ថាប្រធានភូមិដើរចែករួចហើយដល់ពេលមកកែគាត់ថាប្រធានភូមិកែរួចហើយ គាត់មិនបានទៅកែទេ ។ ច្បាប់ គជប បានកំណត់ថាបើខុសអក្ខរាវិរុទ្ធ ខុសឈ្មោះត្រូវមកកែនៅកន្លែងស្មៀន ដល់គាត់គិតថាមេភូមិកែរួចហើយ ដល់ពេលមកបោះឆ្នោតឈ្មោះគាត់មានខុស នេះជាបញ្ហា ។

**លោក សៅ សារ៉ាត** សមាជិកក្រុមប្រឹក្សាឃុំ មកពីគណបក្សប្រជាជនកម្ពុជា បានបញ្ជាក់ជូនរឿងផ្តល់ព័ត៌មានដែលថាមានការរើសអើងមិនផ្តល់ឱ្យដល់ប្រជាពលរដ្ឋ លោកផ្ទាល់ចុះចែកគឺធ្វើយ៉ាងម៉េចចែកឱ្យអស់ពីក្នុងសៀវភៅនីមួយៗ ។ យើងអាចសួរគណបក្សតំណាងនៅក្នុងឃុំក្រចេះ តើក្រុមប្រឹក្សាមានការរើសអើងដែលឬទេក្នុងការផ្តល់ប័ណ្ណព័ត៌មាន លោកផ្ទាល់បានដើរពីផ្ទះមួយទៅផ្ទះមួយ ប៉ុន្តែអ្នកខ្លះចូលមកគឺមិនមាន ហើយមិនមានឯកសារអ្វីជាភស្តុតាងថាជាប្រជាជន ម្យ៉ាងទៀតអ្នកដែលផ្លាស់ទៅមិនមានប្រាប់ខាងរដ្ឋអំណាចលោក ថាផ្លាស់ទៅណាទេ ។ លោកគ្រាន់តែពិនិត្យមើលលើការផ្តល់ព័ត៌មានគ្រាន់តែស្លាប់ និងផ្លាស់ចេញប្រហែលជា១០០ នាក់ ហើយលោកបានរកហើយបានប្រាប់ទៅគណបក្សនីមួយៗដែលនៅក្នុងឃុំ សូមថាបើស្គាល់ឈ្មោះនេះលោកនិងទៅ ឬមេភូមិទៅ មិនមានការរើសអើងទេ ។

**លោក អ៊ុល គឹមណេង** តំណាងគណបក្ស សម រង្ស៊ី ខេត្តក្រចេះ ចំពោះចំណុចដែលលោកសុផល និងអ៊ីវ៉ាតបានមានប្រសាសន៍ លោកសូមបញ្ជាក់បន្ថែមថា ពិតហើយក្រុមប្រឹក្សាឃុំ និងប្រធានភូមិបានផ្សព្វផ្សាយតាមនីតិវិធី ក៏ប៉ុន្តែគាត់មិនបានចុះជាប់រហូតដល់គ្រប់ផ្ទះទេ គាត់បានធ្វើការបែងចែក ដោយចែកទៅឱ្យភូមិ និងអនុភូមិ ពេលនោះភូមិដែលទើបតែជាប់ឆ្នោតថ្មីៗ ទី១ គាត់មិនទាន់យល់អំពីនីតិវិធីនៃការផ្តល់ព័ត៌មាន និងការចុះឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ណាមួយទើបតែជាប់ថ្មីៗគាត់ខ្លាច អញ្ចឹងត្រង់នេះហើយដែលថាមិនតម្លាភាព ។ ជាក់ស្តែងនៅក្នុងគ្រួសារលោកផ្ទាល់មេភូមិស្នួលបានយកប័ណ្ណព័ត៌មានចែកជុំវិញ ប៉ុន្តែចំពោះម្តុំគ្រួសារលោកដែលដឹងថាលោកជាគណបក្សសមរង្ស៊ីមិនបានចែកទេ ប៉ុន្តែមានជំទប់ឃុំ ក្រុមប្រឹក្សាឃុំបានសួរលោកថា ហេតុអ្វីបានលោកមិនមានឈ្មោះនៅក្នុងបញ្ជី លោកនៅក្នុងឃុំស្នួល មានតែប្រពន្ធ ប្អូន ខ្លួនឯងមិនមាន លោកក៏បានទៅពិនិត្យឈ្មោះ លោកបានទៅចុះឈ្មោះនៅឃុំអូរឬស្សី ។

ចំពោះបញ្ហាប្តូរទីលំនៅ គឺពាក់ព័ន្ធនិងក្រុមប្រឹក្សាឃុំសង្កាត់ មានឃុំសង្កាត់មួយចំនួនយល់ ហើយឃុំសង្កាត់មួយចំនួនអល់អែកគឺគាត់ខ្លាច ។ ជាក់ស្តែងលោកផ្ទាល់បានផ្ទេរឈ្មោះទៅឃុំផ្សើម ទម្រង់ ១០១៩ឃុំវាយត្រារួចហើយលោកមិនទាន់ចុះឈ្មោះ លោកចង់ដឹងថាតើស្មៀនមានសមត្ថភាពដែលឬទេ ពេលនោះគាត់មិនចុះឈ្មោះឱ្យលោកគាត់ថាដូចជាមិនគ្រប់នីតិវិធី ហើយលោកឱ្យសួរខាង គជប តែលោកមានកន្ទុយប័ណ្ណព័ត៌មានមកពីការិយាល័យ ០០៩៣ ឃុំអូរឬស្សី លេខកូដ ១៨ លោកបានឱ្យទៅគាត់ តែគាត់ថាមិនហ៊ានចុះទេទាល់តែសួរលោកស៊ីយឿន ក្រោយមកលោកស៊ីយឿនថាចុះឱ្យបាន នេះបានន័យថាពាក់ព័ន្ធរឿងមិនតម្លាភាព ។

លោកបានជំរាបសួរទៅលោកស៊ីយឿនថា ខេត្តក្រចេះបញ្ហាចុះឈ្មោះនៅដំណាក់កាលកន្លងមកគ្មានពាក្យបណ្តឹងតវ៉ា និងជំទាស់ទេ ប៉ុន្តែលោកបាននិយាយការចុះឈ្មោះនីមួយៗក្នុងបញ្ជីគាត់ពិនិត្យល្អិតល្អន់ណាស់មុននិងចុះពិតជាសញ្ជាតិខ្មែរ លោកត្រេកអរណាស់ លោកបានសួរបញ្ជាក់ទៅលោក អ៊ុំ ភី តំណាងស្នងការខេត្ត ថាបញ្ហាអត្តសញ្ញាណប័ណ្ណលោកបានបញ្ជាក់ហើយថាធ្វើបណ្តើរៗហើយមានខ្វះចន្លោះ តែលោកក៏បញ្ជាក់ថា តើអន្តោប្រវេសនៅក្នុងខេត្តក្រចេះមានចំនួនប៉ុន្មាន? អន្តោប្រវេសន្តសុទ្ធប៉ុន្មាន? អន្តោប្រវេសតូបនីយកម្មប៉ុន្មាន? មិនមែនអន្តោប្រវេសន្តសុទ្ធប៉ុន្មាន? ជនជាតិភាគតិចមានចំនួនប៉ុន្មាន? អន្តោប្រវេសន្តទាំងនោះសំគាល់លើអ្វី? អ្វីជាជនជាតិខ្មែរពិតប្រាកដ? ។ លោក បានសួរទៅលោកស៊ីយឿនថា តើនៅក្នុងបញ្ជី គជប ខេត្តក្រចេះមានពាក់ព័ន្ធជនអន្តោប្រវេសន្ត ដែលមានឈ្មោះពីមុនរហូតមកដល់បច្ចុប្បន្ន នៅពេលដែលដូរប័ណ្ណបោះឆ្នោតមកអត្តសញ្ញាណប័ណ្ណវិញ ។

លោកក៏បានបញ្ជាក់ទៅលើអង្គការប្រតិបត្តិពីបញ្ហាទំនាស់ ជាក់ស្តែងនៅឃុំស្នួល ក្រុមប្រឹក្សាឃុំ មេភូមិផ្តងប្រជុំនៅក្នុងក្រុមប្រឹក្សាឃុំថាត្រូវជំរាបជូនមេភូមិឱ្យប្រាប់គាត់ដើម្បីធ្វើការប្រជុំ និងប្រាប់ប្រជាពលរដ្ឋឱ្យមកចុះឈ្មោះដោយមានឯកសារផ្សេងៗដែលពាក់ព័ន្ធ ។ ហើយគាត់ទៅប្រាប់ថាមកប្រជុំ ដល់មកប្រជុំក្រុមប្រឹក្សាឃុំស្នួលទាំងអស់គាត់ថាគាត់និយាយនៅក្នុងអង្គប្រជុំ ហេតុអ្វីបានប្រាប់គាត់ថាមកប្រជុំ អញ្ចឹងខ្វះចន្លោះធ្វើឱ្យគាត់ខាតពេលវេលា នាំឱ្យគាត់ធុញទ្រាន់ក្នុងការចុះឈ្មោះ ពេលនោះនាំឱ្យមានការជេរគ្នា ។ ក្រោយមកសួរថាប្តឹងទៅនរណា នេះមិនអាចប្តឹងមកលោកស៊ីយឿនបានទេ ព្រោះមិនមែនជានីតិវិធីចុះឈ្មោះទេជារឿងក្រៅ ។ លោកសំណូមពរឱ្យអង្គការប្រតិបត្តិ ដែលជាទីប្រឹក្សារបស់ឧបនាយកក្រសួងមហាផ្ទៃ ពេល គជប មិនបានចុះបញ្ជីឈ្មោះ ផ្សព្វផ្សាយព័ត៌មានកន្ទុយប័ណ្ណ ពេលចុះបោះឆ្នោត ពេលឃោសនាក៏ដោយ សូមឱ្យមានប៉ូលីសអព្យាក្រិត ហើយស្លៀកពាក់ជាស៊ីវិល ដើម្បីកត់ទុកបង្ការនៅពាក្យញុះញង់ក្រៅសៃវៀនវង្វង់ចុះឈ្មោះ និងបោះឆ្នោត ដើម្បីសំរបសំរួលលើមតិញុះញង់ វាជាប់ពាក់ព័ន្ធនិងបទរដ្ឋប្បវេណី និងព្រហ្មទ័ណ្ឌ ។

**លោក ឱក សេរី សោភ័ក្តិ** បានបញ្ជាក់ប្រាប់អង្គប្រជុំកាលដែលលោកធ្វើជាទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង ពីឆ្នាំ ១៩៩៣-១៩៩៩ បន្ទាប់មកជាទីប្រឹក្សារបស់អង្គការអន្តរជាតិធំៗ ដែលឯករាជ្យសុទ្ធសាធ លោកគ្មានបំរើគោលការណ៍គណបក្សណាទាំងអស់ អញ្ចឹងបានជាយន្តការខប់សែលបានទទួលស្គាល់ពីគណបក្ស សម រង្ស៊ី ដែលលោកជាមិត្តភ័ក្ត្ររបស់ឯកឧត្តម សម រង្ស៊ីនៅស្រុកបារាំង ហើយអង្គការខុមហ្វ្រែល និកហ្វិច ក៏បានទទួលស្គាល់ថាវិទ្យាស្ថាន CDRI និងយន្តការខប់សែលនេះមិនមានប្រកាន់និន្នាការនយោបាយណាទាំងអស់ ។

**លោក វ៉ាន់ ឡឿន** ក្រុមប្រឹក្សាឃុំស្ទួល តំណាងគណបក្សប្រជាជនកម្ពុជា រឿងអត្តសញ្ញាណប័ណ្ណដែលមានការភ័យព្រួយគ្រប់គណបក្សទាំងអស់ ទី១ ខ្លាចថាអត្តសញ្ញាណប័ណ្ណមកមិនទាន់ពេលបោះឆ្នោត។ ទី២ ខ្លាចអត្តសញ្ញាណប័ណ្ណចេញមកទាន់ពេល ហើយតែខុស ព្រោះនៅក្នុងអត្តសញ្ញាណប័ណ្ណកន្លងមកមានខុសអក្ខរាវិរុទ្ធ ថ្ងៃខែ ។ តាមលោកសង្កេតមើលការខុសនេះ ទី១ មួយចំនួនតូចនគរបាលគាត់សរសេរខុស ទី២ បងប្អូនប្រជាពលរដ្ឋឆ្លើយតាមចិត្តគាត់ ម្តងថាឈ្មោះនេះ ម្តងថាឈ្មោះនោះ ហើយមិនចាំថ្ងៃខែកំណើតនេះជារឿងពិត ព្រោះលោកផ្ទាល់បានចុះទៅធ្វើអត្រានុកូលដ្ឋាន គឺអត្តសញ្ញាណប័ណ្ណប័ណ្ណបោះឆ្នោត សៀវភៅគ្រួសារ ទាំង៣នេះខុសគ្នាទាំងអស់ ។ សួរថាតើសំរេចឱ្យគាត់ធ្វើរបៀបណា អញ្ចឹងសំណូមពរគាត់ថាយកមួយណាដែលត្រូវ ។ លោកបានស្នើទៅខាងនគរបាលធ្វើយ៉ាងណាឱ្យអត្តសញ្ញាណប័ណ្ណបានទាន់ពេល ។

នៅឃុំស្ទួលមានគណបក្សប្រជាជន គណបក្សសមរង្ស៊ី គណបក្សហ្វ៊ុនស៊ីនប៉ិច មិនមានទំនាស់ផ្ទៃក្នុងអ្វីទេ រួមគ្នាធ្វើយ៉ាងណាសំរួលដល់ប្រជាជនឱ្យចុះឈ្មោះឱ្យបានច្រើន នាំឱ្យលើកនេះការចុះឈ្មោះនៅឃុំស្ទួលមានអត្រាកើនឡើងច្រើន ប៉ុន្តែយើងមានបញ្ហារឿងប័ណ្ណព័ត៌មាន ដោយសារការផ្សព្វផ្សាយយឺតទាំងសមាជិកក្រុមប្រឹក្សាឃុំធ្វើការផ្សព្វផ្សាយមិនបានទូលំទូលាយ នៅមានការខ្វះខាត មិនដូចជំនាន់អ៊ុនតាក់ការផ្សព្វផ្សាយបានទូលំទូលាយ ព្រោះគេមានថវិការច្រើន ។ ម្យ៉ាងវិញទៀតប្រធានភូមិមានកំរិតវប្បធម៌ទាបអ្នកខ្លះយល់ អ្នកខ្លះមិនយល់ អញ្ចឹងឱ្យគាត់យកប័ណ្ណព័ត៌មានទៅចែក ជួនកាលបានជួនកាលមិនបាន ។ លោកបានបដិសេធនឹងលើបញ្ហាដែលថា ការចែកប័ណ្ណព័ត៌មានដោយកន្លែង បញ្ហាត្រង់ថាមេភូមិឡើងថ្មីស្គាល់ប្រជាជនមិនទាន់អស់ទេ ។ នៅភូមិមានការពិបាកដោយសារប្រជាពលរដ្ឋមិនសូវមានចំណេះដឹង ហេតុដូចនេះហើយនាំឱ្យពិបាកដល់ការធ្វើការ ។

ពាក់ព័ន្ធនិងទម្រង់ ១០១៨ ដែល គជប ឱ្យចេញរូបថតដោយខ្លួនឯង នេះជារឿងមួយដែលប៉ះពាល់គ្នាបន្តិចបន្តួចរវាងគណបក្សមួយទៅគណបក្សមួយ អញ្ចឹងរាល់គណបក្សមួយត្រូវទទួលខុសត្រូវលើបញ្ហានេះ គឺថតឱ្យសមាជិករបស់ខ្លួន ។ កន្លងមកក៏មានពាក្យចចាមអារាមថាលោកអូសទាញសមាជិកគណបក្សផ្សេងមកថតនៅគណបក្សលោក ប៉ុន្តែតាមពិតប្រធានភូមិ ប្រធានក្រុមខ្លះក្តាប់សមាជិកខ្លួនឯងមិនអស់ដែរ ឧបមាថាគណបក្សសមរង្ស៊ីទៅថត គាត់មិនបានប្រាប់ថាថតឱ្យសមាជិកគណបក្សគាត់ទេ គាត់ថាថតបោះឆ្នោត ហើយប្រជាជនកំពុងតែជ្រួលច្របល់ចង់បោះឆ្នោត ឃើញគេថតផ្អើលទៅថតដែរ អញ្ចឹងនាំឱ្យមានពាក្យថាមួយទាញមួយ ។ លោកផ្ទាល់គណបក្សប្រជាជនពេលទៅថតលោកបានប៉ាដាពណ៌ខៀវ ហើយបិទរូបគណបក្សប្រជាជនឆ្វេងស្តាំតែម្តង ហើយមានបងប្អូនចូលថតច្រើនលោកបានជំរាបថា លោកធ្វើនេះគឺថតសមាជិកគណបក្សប្រជាជន បើអ្នកណាមិនមែនសូមថតផ្សេង ។

ពាក់ព័ន្ធនិងបញ្ហាដែលខាងគណបក្សសមរង្ស៊ីបានលើកឡើងថា មានប្រជាជនមកពីភូមិក្រោមម្នាក់ គាត់ត្រូវធ្វើអត្តសញ្ញាណប័ណ្ណ ប៉ុន្តែនគរបាលមិនធ្វើឱ្យ ដោយសារឱ្យគាត់ផ្លាស់ទីលំនៅសិន លោកបានជំរាបថានៅក្នុងឃុំស្ទួលមានប្រជាជនច្រើនណាស់ មានអ្នកមកថ្មីតែមិនដឹងមកពីណាខ្លះទេ ខ្លះមកនៅ២ឆ្នាំហើយតែភូមិ ឃុំមិនទាន់ដឹង គាត់ចូលមកនៅស្រេចតែចិត្តគាត់ គាត់មិនប្រាប់មេ

ភូមិណាទេ មានអ្នកមិនមានឯកសារសូម្បីតែ១សន្លឹក អញ្ចឹងនគរបាលដែលមិនធ្វើឱ្យគឺជាជំនាញរបស់នគរបាលទេ ។ លោកបានបញ្ជាក់ថាបញ្ហានេះមិនមានប៉ះពាល់ទៅដល់ការរើសអើងទេ ។

ចំពោះរឿងដែលគាត់សូមសំបុត្រផ្លាស់ទីលំនៅ ហើយភូមិ ឃុំ ស្រុក នគរបាលយកលុយ លោកបានបដិសេធន៍ថានៅឃុំស្នួលមិនមានទេ បើសិនគោក្របីផ្លាស់ទីលំនៅអាចយក ព្រោះគាត់ដឹកក្របីពីភូមិមួយទៅលក់នៅភូមិមួយទៀត ។

**លោក ខៀវ បូរ** ជំទប់ទី២ ឃុំសំបូរ ស្រុកសំបូរ គណបក្ស សមរង្ស៊ី បានសួរថាកាលដែលគណបក្សមួយៗទៅថតរូប តើពាក់ព័ន្ធដល់ការសំងាត់នៃការបោះឆ្នោតដែលឬទេ? ព្រោះបើតាមលោកដឹងបើគណបក្សមួយដឹងថានេះសមាជិកខ្លួនហើយចាំបាច់បោះឆ្នោតធ្វើអី ។

លោកបានឯកភាពលើបញ្ហាមួយចំនួនដែលថាប្រជាពលរដ្ឋមិនព្យាយាម ឬមិនភ្ញាក់រលឹកទៅធ្វើប័ណ្ណ ប៉ុន្តែសព្វថ្ងៃមានបញ្ហាច្រើនណាស់ច្របូកច្របក់រឿងប័ណ្ណ ព្រោះមិនដឹងថាប័ណ្ណណាជាប័ណ្ណណាទេ ហើយចំណេះដឹងប្រជាពលរដ្ឋនៅមានកំរិត ។ មុននិងចុះឈ្មោះបោះឆ្នោតមានចែក មានធ្វើអត្តសញ្ញាណប័ណ្ណ ការផ្តល់ប័ណ្ណព័តិមាន នាំឱ្យមានការច្របូកច្របល់ នៅមូលដ្ឋានមានការមមាញឹកណាស់ ពិសេសស្មៀនឃុំជួនកាលគាត់ធ្វើការងារមិនទាន់ ។

លោកក៏បានលើកពីបញ្ហាទំនាស់ដែលកើតមានកន្លងមកក្នុងពេលបោះឆ្នោត ទំនាស់កើតឡើងមកពីការមិនគោរពច្បាប់ បើទាំងអស់គ្នាគោរពច្បាប់គឺមិនមានទំនាស់ទេ ។ ការមិនគោរពច្បាប់មាន ២ ទី១ មិនដឹង ទី២ បំពាន ។ កន្លងមកសង្កេតឃើញថាអាជ្ញាធរភូមិ ឃុំ បញ្ហាមូលដ្ឋានបើយើងគិតថាគ្រាន់តែមកមានបញ្ហាអី នេះមិនត្រូវទេ ព្រោះនៅមូលដ្ឋានមានអារម្មណ៍ខុសពីយើង គាត់មានការខ្លាចក្រែង ។ កន្លងមកមេភូមិ បេក្ខជននៅច្របូកច្របល់ក្នុងការិយាល័យបោះឆ្នោតដោយយកលេសថាទៅពិនិត្យឈ្មោះ ជួយពិនិត្យឈ្មោះ ឬជួយរកការិយាល័យ លើកនេះសូមកុំឱ្យមានបែបនេះទៀត លោកត្រេកអរណាស់ដែល គជប មានដាក់ភ្នាក់ងារម្នាក់សំរាប់ជួយពិនិត្យឈ្មោះ ។

**លោក ឱក សេរី សោភក្តិ៍** បានជំរាបអង្គប្រជុំថានៅពេលដែលខប់សែលធ្វើការជាមួយក្រសួងមហាផ្ទៃ និងអាជ្ញាធរមូលដ្ឋានទាំងអស់ អាជ្ញាធរខេត្ត អាជ្ញាធរស្រុក តាមរយៈខប់សែលប្រ៊ម និងអាជ្ញាធរភូមិ ឃុំ ជាមួយនិងគណបក្សធំៗ អង្គប្រជុំបានឯកភាពគ្នាថានៅជុំវិញស្ថានីយបោះឆ្នោត ស្នើសុំកុំឱ្យមានវត្តមានរបស់អាជ្ញាធរមូលដ្ឋានដូចកន្លងពេលមក កុំឱ្យថាអាជ្ញាធរជួយអ្នកមើលឈ្មោះអ្នកបោះឆ្នោត ព្រោះបើគាត់នៅក៏មិនចំណេញអីដែរ តែបើខាតមានច្រើនណាស់ អ្នកសង្កេតការណ៍ជាពិសេសអ្នកសង្កេតការណ៍អន្តរជាតិយកទៅលើកឡើងនៅថ្នាក់ជាតិច្រើន ។ អញ្ចឹងហើយបានជាក្រសួងមហាផ្ទៃ គជប និងអាជ្ញាធរមូលដ្ឋានតាមលំដាប់ថ្នាក់ឯកឧត្តមអភិបាលខេត្តដែលខប់សែលបានជួបនៅគ្រប់ខេត្ត ឯកភាពថានៅពេលបោះឆ្នោតឆ្នាំ ២០០៧-២០០៨ មិនឱ្យមានវត្តមានរបស់អាជ្ញាធរភូមិ ឃុំនៅជុំវិញការិយាល័យបោះឆ្នោត ដើម្បីនៅចាំឱ្យព័តិមានដល់អ្នកបោះឆ្នោតទេ ។ គជប ដើម្បីជំនួសកិច្ចការនេះបានថែមសមាជិកម្នាក់ទៀតដើម្បីឱ្យជួយនៅក្រៅស្ថានីយបោះឆ្នោតសំរាប់ជួយប្រជាពលរដ្ឋ ជាពិសេសអ្នកដែលមិនសូវចេះអក្សរ ខ្វះងងឹតភ្នែក ។

**លោក គង់ ហ៊ុល** សមាជិកក្រុមប្រឹក្សាគណបក្សសម រង្ស៊ីខេត្តក្រចេះ ពាក់ព័ន្ធនិងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះពីថ្ងៃ ០១ ដល់ថ្ងៃ ២០ រហូតដល់បន្តទៅ ៤ថ្ងៃ សរុបទៅ ២៤ថ្ងៃ ប៉ុន្តែព័តិមានផ្សព្វផ្សាយពី គជប នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះនេះគ្រាន់តែពីថ្ងៃ ០១ដល់ ២០ ចំណាយពេល ៥ថ្ងៃទំរាំតែបានព័តិមានហៅគណបក្សនយោបាយទៅប្រជុំនៅ PEC ហើយនាំគណបក្សនយោបាយបញ្ជូនព័តិមានពី PEC ផ្សព្វផ្សាយទៅក្រុមប្រឹក្សាឃុំសង្កាត់របស់គណបក្សនយោបាយ អស់រយៈពេល ៣ថ្ងៃទៀត ដូច្នេះ

មានតែ១២ថ្ងៃទេដែលបានទៅចុះឈ្មោះ ។ នេះព័ត៌មានមានការយឺតយ៉ាវពាក់ព័ន្ធនិង គខប និង គជប ។ តាមរយៈខប់សែលលោកបានសំណូមពរថា សុំឱ្យខប់សែលយកបញ្ហានេះទៅពិភាក្សាជាមួយ គជប ថាបើផ្តល់ព័ត៌មានពីបញ្ហាពាក់ព័ន្ធនិងការងារបោះឆ្នោតនៅតាមខេត្តសុំឱ្យបញ្ជូនមុនរយៈពេលកន្លះខែ ឬមុន១សប្តាហ៍ ដើម្បីងាយឱ្យគណបក្សនយោបាយទាំងអស់ធ្វើការប្រជុំគណបក្សគាត់ ផ្សព្វផ្សាយឱ្យគណបក្សថ្នាក់មូលដ្ឋានដឹងបានទាន់ពេល ។ នៅពេលបន្តិចទៀតត្រូវដាក់ពាក្យក្រុមប្រឹក្សាឃុំសំរាប់ឆ្នាំ ២០០៧ តារាងប្រតិទិនគេដាក់ខែធ្នូ ហើយការពិនិត្យគេបោះជាសៀវភៅឱ្យ តែការផ្សព្វផ្សាយមិនទាន់មានទៀត ។ ពិនិត្យប្រតិទិនមិនទាន់ដល់គណបក្សនយោបាយ នេះជិតដល់ពេលហើយត្រូវត្រៀមបេក្ខភាពឈរឈ្មោះ ។

បញ្ហាមួយទៀតរយៈពេលកន្លងមកគណបក្សទាំង៣មាននៅ គជប ប៉ុន្តែ គខប មិនមាន សួរថាតើនីតិវិធីគេធ្វើរបៀបយ៉ាងម៉េច? ពាក្យថារដ្ឋាភិបាលដឹកនាំប្រជាធិបតេយ្យ ។ លើកមុនគណបក្សសមរង្ស៊ីបានដាក់ពាក្យនៅ គខប បានឆ្លងកាត់ការធ្វើតេស្ត តែលទ្ធផលចេញមកធ្លាក់ អញ្ចឹងមិនបាច់ប្រកាសថាធ្វើប្រជាធិបតេយ្យ ហើយប្រកាសឱ្យដាក់ពាក្យធ្វើអី បើថាគណបក្សនយោបាយណាដែលធ្លាប់ធ្វើយកគាត់តែម្តងទៅ មិនបាច់បោះឆ្នោតសច្ចៈធម៌ យុត្តិធម៌ ត្រឹមត្រូវទេ ។ បើ គជប មាននៅ គខប ត្រូវតែមានដែរ ហើយនៅតាមឃុំនីមួយៗ គឃប ក៏ត្រូវតែមានដែរ នេះទើបហៅថាស្មើភាព ប្រជាធិបតេយ្យ នេះទើបបានអស់ទំនាស់ក្នុងការបោះឆ្នោត ។ យើងយល់ថាប្រជាធិបតេយ្យប្រទេសយើងអាចទៅហើយ បើកសិទ្ធិទូលំទូលាយឱ្យប្រជាពលរដ្ឋ គាត់ជាប្រជាជនរបស់រដ្ឋ មិនមែនប្រជាជនរបស់គណបក្សនយោបាយណាមួយទេ ។ ឥឡូវនេះមានគំនាបពីគណបក្សនយោបាយ គណបក្សសមរង្ស៊ីមិនហ៊ានធ្វើអ្វីទេ គំនាបពីគណបក្សដែលមានអំណាច ពេលទៅធ្វើគាត់ថាមិនបាច់ថតទេ ផ្តិតមេដៃឱ្យគាត់ បើមិនបោះឆ្នោតឱ្យគេគាត់មិនឱ្យអំណោយទេ ហើយប្រជាជនចង់បោះឆ្នោតគណបក្សសមរង្ស៊ីឬគណបក្សហ៊្វុនស៊ិនប៉ិច ហើយគាត់ថាបោះយ៉ាងម៉េចបើគេចាប់គាត់ផ្តិតមេដៃ ដូច្នេះប្រជាពលរដ្ឋម្នាក់ គឺអស់សិទ្ធិនៅក្នុងមូលដ្ឋានមួយៗ ដែលគាត់មានសិទ្ធិបោះឆ្នោតតែគាត់ខ្លាច ។

ថ្មីៗនេះការគំរាមកំហែងក៏មាន ហើយព័ត៌មាននេះលោកកំពុងតែធ្វើបទរដ្ឋានឱ្យច្បាស់ ដើម្បីដាក់ពាក្យបណ្តឹងនៅក្នុងខេត្ត គឺថ្ងៃទី១១ខែ វិច្ឆិកា មានការគំរាមកំហែងពីយោធានៅស្រុក ព្រែកប្រសព្វគំរាមដល់ជំទប់ទី១ របស់គណបក្សសមរង្ស៊ី ឈ្មោះអ៊ុំ មឿកនៅឃុំសោក បង្ខំឱ្យគាត់ចុះចេញពីតំណែង គេគំរាមថាបើមិនចុះទេគេនឹងគាប ព្រោះកូនគាត់នាយកសាលានៅឃុំសោក ។ ព័ត៌មានលោកកំពុងតែស្រាវជ្រាវ យកឈ្មោះឱ្យពិត នៅអង្គភាពណា ពាក់ព័ន្ធនិងប៉ូលីស ឬទាហ៊ាន លោកនឹងធ្វើតាមផ្លូវច្បាប់ ។

បញ្ហាមួយទៀតជំទប់គណបក្សសមរង្ស៊ីបានរាយការណ៍មកថា មានយួនមកចុះអត្រានុកូលដ្ឋាននៅឃុំក្រចេះ យួនដូរឈ្មោះទៅជាខ្មែរ បញ្ហានេះលោកក៏កំពុងតែស្រាវជ្រាវដែរ ។

លោកស្រី **គា ប៊ុណ្ណារី** សមាជិកក្រុមប្រឹក្សាខេត្ត គណបក្សសម រង្ស៊ី បានជំរាបសួរទៅលោកស្នងការរឿងអត្តសញ្ញាណប័ណ្ណដែលបានទទួលហើយបាត់ទៅវិញ នេះអត្តសញ្ញាណប័ណ្ណដែលមានឈ្មោះខុសនៅក្នុងសំបុត្រកំណើត ហើយប្រជាពលរដ្ឋបានសុំដូរ តែលោកប៉ូលីសថាយក ២០ដុល្លា ។ ចំពោះប្រជាពលរដ្ឋដែលមានជីវភាពធូរធារមិនមានបញ្ហាចោទទេ ប៉ុន្តែចំពោះអ្នកដែលក្រីក្រ លំបាកដែលរកតែបាយហូបមិនបានផង តើគាត់បាន ២០ដុល្លាមកពីណាយកមកធ្វើ ដូចនេះគាត់មិនបានធ្វើអត្តសញ្ញាណប័ណ្ណរហូត ។

លោក **ខៀវ បូ ជំទប់ទី២ ឃុំសំបូរ ស្រុកសំបូរ** បានមានប្រសាសន៍ថា គជប ផ្លាស់ប្តូរពីប័ណ្ណបោះឆ្នោតត្រឡប់មកយកអត្តសញ្ញាណប័ណ្ណវិញ តើបញ្ហានេះងាយស្រួលដល់ប្រជាពលរដ្ឋយ៉ាងដូចម្តេចខ្លះ ហើយមានផលចំណេញអ្វីខ្លះ? បើសិនជាការប្តូរប័ណ្ណបោះឆ្នោតមកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លោកយល់ថានេះជាការស្មុគ្រស្មាញ ត្រង់ថាការបោះឆ្នោតកន្លងមកហេតុអ្វីបានជាប័ណ្ណបោះឆ្នោតចេះតែមានសុពលភាពមក ហើយនៅក្នុងប័ណ្ណមានលេខកូដការិយាល័យ លេខកូដឃុំ អញ្ចឹងពេលគាត់មើលប័ណ្ណគាត់ដឹង

លេខកូដរបស់គាត់ ឧទាហរណ៍ ឃុំក្រចេះ ការិយាល័យលេខ ០០៨២ មានលេខរៀងប៉ុន្មាន ដល់ពេលប្តូរមកអត្តសញ្ញាណប័ណ្ណមិនមានលេខកូដនៅក្នុងនោះ អញ្ចឹងដល់ថ្ងៃបោះឆ្នោតនាំឱ្យជួបបញ្ហាច្របូកច្របល់ ។ លោកបានសំណូមពរទៅតំណាងស្នងការនគរបាលខេត្តពាក់ព័ន្ធនិងអត្តសញ្ញាណប័ណ្ណសូមជួយអន្តរាគមន ករណីនៅស្រុកសំបូរ មានក្រុមជំនាញចុះធ្វើដល់ពេលគៀងគរប្រជាពលរដ្ឋមកធ្វើបានហើយ ស្រាប់តែមានបញ្ហារឿងថតខ្លោចនាំឱ្យខូចរូបថតច្រើន ហើយការធ្វើឡើងវិញនាំឱ្យមានការយកលុយពីប្រជាពលរដ្ឋ លោកបានសួរទៅមន្ត្រីជំនាញថា ហេតុអ្វីបានយកលុយ គាត់ថាបើមិនយកបានបាយឯណាហូប ព្រោះថ្នាក់លើមិនមានផ្តល់លុយសំរាប់ចុះបេសកម្ម ។ ចំពោះប្រជាពលរដ្ឋនៅទីក្រុងមិនអីទេ តែសំរាប់អ្នកដែលនៅជនបទ ជាពិសេសជនជាតិទៀតពិបាកណាស់ នាំឱ្យមានការលំបាក ។

ពាក់ព័ន្ធនិងបញ្ជីឈ្មោះថ្មី និងការិយាល័យបង្កើតថ្មី ចំពោះការិយាល័យបង្កើតថ្មីឃើញមិនទាន់មានប្រជាពលរដ្ឋដែលត្រូវយកទៅដាក់ទេ ការិយាល័យមិនទាន់មានចំនួនពិតប្រាកដថាប៉ុន្មានទេ អញ្ចឹងប្រជាពលរដ្ឋលេខរៀងទីប៉ុន្មាន ឈ្មោះនៅកន្លែងណាការិយាល័យលេខប៉ុន្មាន គាត់មិនទាន់ដឹង សូមឱ្យខាងលេខាធិការដ្ឋានបកស្រាយពីបញ្ហានេះ ។

លោកស្រី **ប៊ុន ចំណាន** តំណាងអង្គការ EDCO និងជាមន្ត្រីសង្កេតការនិកហ្វិច នៅក្នុងភូមិឃុំរបស់លោកស្រីការធ្វើការខ្លះមិនមានតម្លាភាព ចំពោះការចុះឈ្មោះបោះឆ្នោត បានទៅចុះឈ្មោះនៅឃុំរួចហើយ មានសកម្មជនមិនដឹងថាគណបក្សណាទេធ្វើការជាសំងាត់គឺប្រមូលអត្តសញ្ញាណប័ណ្ណ និងប័ណ្ណគ្រួសារ ព្រមទាំងថតរូបនៅតាមកន្លែងខ្លះ ប៉ុន្តែគេធ្វើចំពោះតែគ្រួសារណាក្រីក្រ ហើយខ្វះការយល់ដឹង ចំពោះគ្រួសារយល់ដឹងគេមិនធ្វើទេ ។ លោកស្រីសង្កេតឃើញថាកន្លែងខ្លះធ្វើការមិនមានតម្លាភាពទេ ជាពិសេសនៅភូមិដាច់ស្រយាល ។

លោក **រស់ សារ៉េត** បានឆ្លើយនិងសំណួរដែលអង្គប្រជុំបានសួរទាក់ទងនិងបញ្ហាអត្តសញ្ញាណប័ណ្ណ និងបញ្ហាជនអន្តោប្រវេស

**ទី១** ការព្រួយបារម្ភរបស់ក្រុមប្រឹក្សាឃុំស្នួលដែលខ្លាចអត្តសញ្ញាណប័ណ្ណចេញមិនទាន់ និងអត្តសញ្ញាណប័ណ្ណដែលខុស លោកបានមានប្រសាសន៍អ្នកផលិតអត្តសញ្ញាណប័ណ្ណគឺក្រុមហ៊ុន ខាងលោកផ្ទាល់ក៏មានការព្រួយបារម្ភដែរ តែយើងគិតថានឹងផលិតទាន់ព្រោះនៅរយៈពេលយូរដែរ អ្វីដែលយើងបារម្ភខ្លាចខុស ។ ការខុសឈ្មោះនេះជួនកាលខាងមន្ត្រីគាត់សរសេរខុស ជួនកាលអ្នកប្រាប់ព័ត៌មានខុស បញ្ហានេះគួរតែពិភាក្សាជាមួយលេខាធិការដ្ឋាន តើមានទម្រង់ផ្សេងសំរាប់ជំនួសការខុសនេះ បើសិនជាផលិតមិនទាន់សំរាប់យកទៅប្រើប្រាស់ពេលបោះឆ្នោត ។

**ទី២** ការដែលមានជនជាតិវៀតណាមធ្វើអត្រានុកូលដ្ឋានសញ្ជាតិខ្មែរ អ្នកដែលធ្វើអត្រានុកូលដ្ឋានគឺមេឃុំជាអ្នកធ្វើ ប៉ូលិសធ្វើតែសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណទេ ។ ច្បាប់សញ្ជាតិគេសរសេរថាកូនដែលកើតក្នុងព្រះរាជាណាចក្រកម្ពុជាពីឪពុក ឬម្តាយជាជនបរទេសដែលកើត និងរស់នៅស្របច្បាប់ក្នុងព្រះរាជណាចក្រកម្ពុជា មួយទៀតកូនដែលគេរើសបានក្នុងព្រះរាជណាចក្រកម្ពុជា នេះច្បាប់ផ្តល់សញ្ជាតិពីកំណើត ។ ពាក់ព័ន្ធជាមួយច្បាប់នេះលោកអាចទាក់ទងជាមួយក្រុមប្រឹក្សាឃុំ ឱ្យគាត់បំភ្លឺពីការធ្វើនេះ ។ លោកទទួលស្គាល់កន្លងមកមានធ្វើមួយនៅឃុំរការកណ្តាល តែលោកបានឱ្យការិយាល័យជំនាញស្ថិតិទៅបញ្ឈប់ហើយ ។

**ទី៣** រឿងអត្តសញ្ញាណប័ណ្ណដែលបានទទួលហើយបាត់ទៅវិញ ដូចលោកបានជំរាបហើយក្រុមហ៊ុនគេផលិតវិញតំលៃ ៥ដុល្លាកាលដែលលើកឡើងថាមានខុសឈ្មោះ ហើយដូរសូម២០ដុល្លា នេះសូមឱ្យលោកស្រីធ្វើជារបាយការណ៍លាយល័ក្ខអក្សរថាឈ្មោះណាដែលធ្វើហើយទារលុយនេះ ។ ស្នងការដ្ឋានរបស់លោកមិនដែលអត់ឱនឱ្យកំលាំងក្រោមឱវាទដែលប្រព្រឹត្តអំពីអ្វីដែលខុសឆ្គងទេ ។

**ទី៤** ចំពោះរឿងជនអន្តោប្រវេស បញ្ហានេះនៅឆ្នាំ ២០០២ បានដំណើរការធ្វើយុទ្ធនាការថ្នាក់ជាតិមួយ ដែលយើងហៅថា យុទ្ធនាការជំរឿនស្ថិតិជនបរទេស យុទ្ធនាការបានបញ្ចប់នៅថ្ងៃ ១៥ ខែវិច្ឆិកា ឆ្នាំ ២០០២ ។ នៅខេត្តក្រចេះបានស្រង់ស្ថិតិឈ្មោះជនបរទេសដែលមានមុខរស់នៅជាអចិន្ត្រៃយ៍មានចំនួន ៦២៨គ្រួសារ ស្មើនិង ២ ៧២៤នាក់ តែមកដល់ពេលបច្ចុប្បន្នយើងដំណើរការជំរឿនមួយទៀត ហៅថាទទួលពាក្យសុំជាជនអន្តោប្រវេស ។ ដូច្នេះអ្នកដែលយើងស្រង់ស្ថិតិពីមុនមកមិនទាន់ជាជនអន្តោប្រវេសទេ យើងគ្រាន់តែសំរង់ស្ថិតិក្នុងបញ្ជីការងារគ្រប់គ្រងតែប៉ុណ្ណោះ ដើម្បីនៅជំហ៊ានទី២ គឺចែកចេញជា២ទៀត ។ ជំហានទី១ ទទួលពាក្យសុំជាជនអន្តោប្រវេសទៅឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជំហ៊ាននេះធ្វើចំពោះជនបរទេសដែលមានឯកសារមុនឆ្នាំ ១៩៧៥ ។ ជំហ៊ានទី ២ ធ្វើអ្នកដែលមានសំរង់ស្ថិតិឆ្នាំ ២០០៣ ។ អញ្ចឹងសិទ្ធិទទួលស្គាល់ថាជាជនអន្តោប្រវេស ឬមិនអន្តោប្រវេស ស្របច្បាប់ ឬមិនស្របច្បាប់ អាស្រ័យដោយឯកឧត្តមក្រសួងមហាផ្ទៃជាអ្នកសំរេច ។ ពេលដែលបានសំរេចជាជនអន្តោប្រវេសស្របច្បាប់ហើយ និងធ្វើពាក្យសុំរស់នៅអចិន្ត្រៃយ៍មួយទៀត ។ ពេលនោះដែលជនបទេសអាយុ ១៨ឆ្នាំឡើងត្រូវបង់អាករជូនរដ្ឋរយៈពេល ២ឆ្នាំ តំលៃ៥០ម៉ឺនរៀលក្នុងម្នាក់ ។ នៅខេត្តក្រចេះពីមុនដូចលោកបានជំរាបហើយជនអន្តោប្រវេសមានចំនួន ៦២៨ គ្រួសារ តែឥឡូវមានចំណាកចេញខ្លះៗ ហើយ តួរលេខពិតប្រាកដដែលមានសព្វថ្ងៃគឺ ៤៥០គ្រួសារ ហើយសរុបមនុស្សដែលមានអាយុ ១៨ឆ្នាំឡើងមានចំនួន ២ ១៦៤នាក់ ។

លោក **អុង ស៊ីយឿន** បានកត់សំគាល់ថាបញ្ហាដែលអង្គប្រជុំបានលើកឡើងមានជាង ៣០ករណី ។ លោកបានឆ្លើយនិងសំណួរពីមុនដែលជាតំណាងគណបក្សសម រង្ស៊ី នៅឃុំស្រែចារ ទាក់ទងនិងប្រជាពលរដ្ឋនៅឃុំអ្នកកណ្តាល បានចុះឈ្មោះហើយ ប៉ុន្តែនៅទីនោះឈ្មោះនៅក្នុងបញ្ជីស្រាប់មានចំនួន ៧០០នាក់ ប្រហែលជាគ្មានឈ្មោះនោះនៅក្នុងបញ្ជី ។ លោកបានជំរាបថានៅក្នុងឃុំសង្កាត់នីមួយៗមានការិយាល័យច្រើន បើសិនជាលោកមើលមិនឃើញនៅការិយាល័យមួយដែលលោកបានកត់សំគាល់ លោកអាចនឹងរកឃើញនៅការិយាល័យមួយទៀត ដែលនៅជិតគ្នានោះ ។

ទាក់ទងបញ្ហាប័ណ្ណព័តិមានបោះឆ្នោត ប្រហែលជាយើងធ្វើមុនគេ ហើយក៏មានបញ្ហាច្រើនដែរ នេះជាការកត់សំគាល់មួយនៅក្នុងការប្រជុំនៅថ្នាក់ជាតិដែលខាងប្រធាន គជប និងទីប្រឹក្សាច្បាប់នៃអង្គការសហប្រជាជាតិក៏បានលើកឡើង ព្រោះនៅប្រទេសជឿនលឿនបើយើងសិក្សាឱ្យបានស៊ីជំរៅនឹងដឹងថាប្រជាពលរដ្ឋរបស់គេមានការជឿនលឿន ការចុះឈ្មោះបោះឆ្នោតគេមិនមានការលំបាកទេ តែអាយុ ១៨ឆ្នាំឡើងគេមានកាតព្វកិច្ចភ្ញាក់រលឹកខ្លួនឯង ហើយបញ្ជីអត្រានុកូលដ្ឋាននៅតាមមូលដ្ឋានគឺច្បាស់លាស់ ។ ចំពោះការបញ្ជូនព័តិមានទៅអ្នកបោះឆ្នោតគេធ្វើតាមរយៈកញ្ចប់ប្រៃសនីយ៍ទៀត តែយើងមិនអាចធ្វើបានដូចគេទេ អញ្ចឹងយើងរកវិធីមួយគឺធ្វើប័ណ្ណព័តិមាន ក្រោយការឯកភាពក៏ដូចជាការផ្តល់យោបល់ពីទីប្រឹក្សាច្បាប់នៃអង្គការសហប្រជាជាតិដែលប្រចាំនៅ គជប ។

ឆ្លើយតបនិងលោក សូត្រ សុផល ដែលបានលើកថាចំពោះទម្រង់ ១០១៨ ហេតុដូចម្តេចបានជា គជប មិនព្រមធ្វើ ហើយប្រគល់រឿងនេះទៅឱ្យប្រជាពលរដ្ឋវិញ ។ បញ្ហានេះជាការតំរូវមួយដែល គជប ថាជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ព្រោះគាត់មានឆន្ទះដើម្បីសំដែងនៅការគាំទ្រណាមួយ ហើយរូបថតមិនចោទជាបញ្ហាទេ គជប ក៏ប្រគល់ការងារនេះឱ្យប្រជាពលរដ្ឋចេញដោយខ្លួនឯងត្រង់ថាជាវិធីណាដើម្បីបានរូបថត នៅក្នុងច្បាប់មិនទាន់បានកំណត់ថាតំរូវយ៉ាងណាទេ ។

បញ្ហាប័ណ្ណព័តិមានមិនមានតម្លាភាព ខាង គខប គ្រាន់តែជាអ្នកសំរបសំរួលទេ រឿងការចែក ជាបច្ចេកទេស អ្នកអនុវត្តយ៉ាងណានោះ នៅក្រុមប្រឹក្សាឃុំ មេភូមិ ។ នៅក្នុងក្រុមប្រឹក្សាឃុំក៏មានតំណាងគណបក្សយើងដែរ យើងអាចពិភាក្សាគ្នាថាត្រូវរៀបចំយ៉ាងម៉េច ។

បញ្ហានីតិវិធីដែលស្មៀនខ្លះបង្កការស្មុគ្រស្មាញ លោកជឿថានៅក្នុងការអនុវត្តន៍ជាក់ស្តែងការខ្វះចន្លោះពិតជាមាន ព្រោះលោកផ្ទាល់បានទៅពិនិត្យដល់ទីកន្លែង ទាក់ទងនិងឥរិយាបថមានស្មៀនខ្លះបំពេញការងារដោយសុភាពរាបសារ ខ្លះក៏មិនបានល្អពេលដែលគាត់ជួបនិងការលំបាកខ្លាំង អាចមានពាក្យសំដីខ្លះធ្វើឱ្យប៉ះពាល់អារម្មណ៍របស់ប្រជាពលរដ្ឋ លោកកទទួលស្គាល់ដែររឿងនេះ ។

អំពីកងកម្លាំងប្រដាប់អាវុធដែលគិតថាកន្លងមកមានទិន្នន័យយ៉ាងណា១នោះ លោកបានធ្លាប់ជួបគ្នានៅក្នុងការប្រជុំឆ្នាំ២០០៣កន្លងមក យើងកបានពិភាក្សាគ្នាដែលនៅក្នុងបញ្ហានេះ បើសិនជាមានបញ្ហាអីយើងអាចជូនព័ត៌មានគ្នាទៅវិញទៅមកដើម្បីដោះស្រាយ បើសិនជាមានករណីណាដែលលោកយល់ថាជាការមិនគួរគប្បី ។

បញ្ហាឈ្មោះ ឬទិន្នន័យនៅក្នុងបញ្ជីបោះឆ្នោត និងប័ណ្ណព័ត៌មាន មានភាពខុសគ្នា លោកគិតថាសំណួរនេះមិនចំបច្ចេកទេសទាំងស្រុងទេ ព្រោះប័ណ្ណព័ត៌មានចំលងចេញពីបញ្ជី ហើយបើមានខុសគឺតិចតួចណាស់ ប៉ុន្តែលោកយល់ថាអ្វីដែលអង្គប្រជុំចង់សួរគឺសួរថាហេតុអ្វីបានជានៅក្នុងបញ្ជីឈ្មោះ ឬព័ត៌មាន មានខុសអក្ខរាវិរុទ្ធ ឬទិន្នន័យខុសគ្នានិងលិខិតបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ដូចជាអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើតឬលិខិតស្នាមផ្សេងទៀត ។ បញ្ហានេះលោកទទួលស្គាល់ថាមានខុសអក្ខរាវិរុទ្ធ និងទិន្នន័យខ្លះ ។ លោកបានបំភ្លឺត្រង់ចំណុចនេះបន្ថែម ព្រោះជាចម្ងល់មួយដែលមានលក្ខណៈសកល ការដែលនាំឱ្យមានការខុស មានកត្តាជាច្រើនដែលសំខាន់១ យើងដឹងហើយថាធម្មតាការចំលងពីការសរសេរដៃ ទៅកុំព្យូទ័រតែងមានខុសខ្លះ ។ កាលពីជំនាន់អ៊ុនតាក់មិនមានបញ្ជីឈ្មោះទេគ្រាន់តែមានប័ណ្ណអាចបោះឆ្នោតបាន តែក្រោយមកដើម្បីបោះឆ្នោតបានត្រូវមានបញ្ជីឈ្មោះ និងមានអត្តសញ្ញាណ អញ្ចឹងបញ្ជីនេះធ្វើឡើងនៅឆ្នាំ ១៩៩៨ សរសេរដោយដៃទាំងស្រុង ហើយយកទៅបោះពុម្ពនៅក្នុងកុំព្យូទ័រ ។ តាំងពីនោះមិនមានការកែតំរូវធំដុំទេនីតិវិធីដើម្បីឱ្យកែតំរូវគ្រាន់តែបិទផ្សាយបញ្ជីចុងក្រោយនៃឆ្នាំបោះឆ្នោតនីមួយ១សំរាប់ប្រជាពលរដ្ឋមើល ថាតើមានខុសដែរទេ ។ ការកែតំរូវដែលមានទម្រង់ធំទើបតែមាននៅឆ្នាំនេះទេ អញ្ចឹងបញ្ជីដែលសរសេរដោយដៃហើយយកទៅបោះពុម្ពគឺនៅមជ្ឈមណ្ឌលកុំព្យូទ័រ ហើយពេលដែលសរសេរនៅដៃមានខ្លះមិនច្បាស់ តើអ្នកនៅខាងកុំព្យូទ័រទៅសួរនរណា ម្ល៉ោះហើយត្រូវតែបង្ខំចិត្តបោះពុម្ព ។ កត្តារួមផ្សំខ្លះទៀតគឺការសុំផ្លាស់ប្តូរឈ្មោះចុះឡើងរបស់សាម៉ីខ្លួន ការផ្តល់ព័ត៌មានមិនច្បាស់លាស់ ឬមិនថេរ ទៅខាងសំបុត្រកំណើតផ្សេង ទៅខាងអត្តសញ្ញាណប័ណ្ណផ្សេង ។

ដោយអង្គប្រជុំចាប់អារម្មណ៍ទៅលើបញ្ហាទម្រង់ការ នៅក្នុងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតនៅឆ្នាំ ២០០៦ ដំបូងនៅក្នុងសៀវភៅណែនាំបានកត់សំគាល់ថា ដើម្បីចុះឈ្មោះប្រជាពលរដ្ឋត្រូវតែមានលក្ខខ័ណ្ឌ ៤ ទី១ អត្តសញ្ញាណប័ណ្ណ ទីលំនៅ សញ្ជាតិ និងអាយុ។ ដើម្បីឈរនៅលើមូលដ្ឋានច្បាប់មួយដ៏រឹងប៉ឹង គជប បានរៀបសៀវភៅណែនាំ ហើយសៀវភៅនេះក៏ដកស្រង់ចេញពីនីតិវិធីដែរនីតិវិធីមុននិងចាប់ផ្តើមឱ្យប្រើ គជប បានត្រៀមរៀបចំ ដោយផ្អែកទៅលើច្បាប់ ។ មុននិងចេញជានីតិវិធី គជប បានដាក់ជូនអ្នកជំនាញច្បាប់ទាំងឡាយដើម្បីរួមគ្នាពិនិត្យមើល និងឯកភាពពីគ្រប់ភាគីនៃគណបក្សនយោបាយ អង្គការសង្គមស៊ីវិល ស្ថាប័នច្បាប់ផ្សេង១ ។

ទាក់ទងនិងការផ្លាស់ប្តូរ នៅពេលដែលការអនុវត្តន៏រឹងស្ទូក ឃើញថាប្រជាពលរដ្ឋមួយចំនួនមិនមានរូបថត អញ្ចឹងគណបក្សនយោបាយទាំងអស់មានប្រតិកម្មភ្លាម បានមកជួបជុំគ្នាធ្វើការដោះស្រាយភ្លាម១ ប៉ុន្តែដោយសារលក្ខណៈនេះធំ យើងគ្រាន់តែបានកំណត់ហេតុនៃការដោះស្រាយមួយ គជប យល់ឃើញថាយើងធ្វើការបោះឆ្នោត គឺតំរូវចិត្តអ្នកដែលចូលរួម ច្បាប់គឺជារឿងមួយហើយ ប៉ុន្តែពេលអនុវត្តមានបញ្ហាយើងត្រូវតែសំរបសំរួលដោះស្រាយ ដោយអនុឡោមលើបញ្ហានេះយើងក៏ប្តូរនីតិវិធីដើម្បីបន្ធូរ គឺពេលនេះបើគាត់មិនទាន់មានរូបថតយើងអាចអនុញ្ញាតឱ្យគាត់ចុះឈ្មោះសិន ហើយនៅពេល២ឬ៣ខែខាងមុខគាត់មានពេលធ្វើទម្រង់ ១០១៨ មានរូបថតយើងអាចដោះស្រាយបាននៅពេលបោះឆ្នោត ។

ឆ្លើយតបទៅនិងខាងតំណាងគណបក្ស សមរង្ស៊ីដែលបានចាប់អារម្មណ៍ពីរឿងតំរិយាបថស្មៀនឃុំ លោកបានជំរាបជូនហើយ អ្វីដែលប្លែកបញ្ហាអន្តោប្រវេសនៅក្នុងបញ្ជីបោះឆ្នោត ។ នៅក្នុង គខប ខេត្តនេះមិនមានឯកសារណាមួយបញ្ជាក់ភ្ជាប់មកជាមួយថាអ្នកនេះជាជនអន្តោប្រវេសនៅក្នុងបញ្ជីបោះឆ្នោតទេ សរុបទៅលោកផ្ទាល់មិនអាចក្តាប់បានថានរណាជាជនអន្តោប្រវេសនៅក្នុងបញ្ជីបោះឆ្នោតទេ ។

លោក **ឱក សេរី សោភក្តិ៍** ដោយបានស្តាប់អង្គប្រជុំមកមានបញ្ហាដែលស្រដៀងគ្នាបានលើកឡើង ហើយដែលលោកនឹងត្រូវធ្វើការងារនេះជាមួយនឹងគណបក្សទាំងអស់នៅថ្នាក់ជាតិ ។ បញ្ហាទាំងអស់នេះបានពន្យល់នៅថ្នាក់ជាតិច្រើនណាស់ជូនទៅខាងគណបក្សនយោបាយនីមួយៗ ដូចជាបញ្ហាថា ហេតុអ្វីបានជាលែងប្រើប័ណ្ណបោះឆ្នោតហើយមកប្រើអត្តសញ្ញាប័ណ្ណវិញ ប៉ុន្តែតាមការដែលស្តាប់នៅកន្លែងនេះ លោកយល់ថាអ្វីដែលបាននិយាយនៅថ្នាក់ជាតិទាំងប៉ុន្មានអត់បានហូរធ្លាក់ចុះតាមខ្សែរគណបក្សមកដល់ថ្នាក់ក្រោមទេ ។ ដូច្នេះនេះជាការខ្វះខាតមួយ ហើយលោកនឹងធ្វើការជាមួយគណបក្ស ។ ខប់សែលប្រជុំនៅថ្នាក់ជាតិបានពន្យល់ និងឱ្យព័តិមានច្រើនណាស់ ហើយសមហេតុសមផលទៀត ប៉ុន្តែមិនបានហូរមកនៅក្នុងកំរិតក្រោមនេះ ។ ដូច្នេះខប់សែលក៏ទទួលស្គាល់ថាទំនាក់ទនងពីលើ ពីថ្នាក់កណ្តាលមកដល់មូលដ្ឋាននៅមានការខ្វះចន្លោះ ដោយឃើញបែបនេះ ខប់សែលគិតថាការរៀបចំខប់សែលប្រ៉មនេះរឹតតែមានតម្លៃទៅទៀត ដើម្បីយកព័តិទាំងអស់មកបកស្រាយនៅថ្នាក់មូលដ្ឋានផ្ទាល់តែម្តង ។

អ្នកស្រី **Margie Cook** តាមទស្សនៈវិស័យរបស់អ្នកស្រី ការលើកឡើងក្នុងកិច្ចពិភាក្សារបស់អស់លោក លោកស្រីក្នុងអង្គប្រជុំនេះ ក៏ដូចជាក្នុងការប្រជុំឯទៀតៗគឺមានលក្ខណៈផុលផុស និងសកម្មខ្លាំង ។ អ្នកស្រីនៅក្នុងនាមតំណាង UNDP នឹងធ្វើការសហការបន្តជាមួយនឹង គជប លើបញ្ហាមួយចំនួនដែលអស់លោក លោកស្រីបានលើកឡើងក្នុងថ្ងៃនេះ ។ បញ្ហាដែលអស់លោកលោកស្រីបានលើកឡើងទាក់ទងទៅនឹងដំណើរការនៃការចែកចាយប័ណ្ណព័តិមានជូនចំពោះអ្នកបោះឆ្នោត និងភាពត្រឹមត្រូវនៅក្នុងប័ណ្ណព័តិមាននោះ ។ ចំណុចសំខាន់មួយទៀត ជុំវិញការចែកចាយព័តិមានពីថ្នាក់ជាតិមកថ្នាក់ខេត្ត ដែលការងារនេះយើងត្រូវគិតគូរឱ្យបានមួយជំហ៊ានទៀតផងដែរ ដើម្បីធ្វើយ៉ាងណាឱ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ។ យើងក៏គួរតែគិតទៅលើថាតើការផ្តល់ជូនព័តិមានទាំងអស់នេះបានជ្រួតជ្រាបដល់ជនជាតិភាគតិចដែលនៅខេត្តក្រចេះដែរឬទេ? ចំណុចទាំងអស់នេះគឺជាការមួយដែលយើងអាចគិតគូរពិចារណានៅពេលដែលយើងរៀបចំការបណ្តុះបណ្តាលវគ្គនានា ជាពិសេសជូនទៅដល់ថ្នាក់ខេត្តក្រុងនានា ហើយនឹងពិភាក្សាពាក់ព័ន្ធទៅនឹងការអប់រំអ្នកបោះឆ្នោត ។ ក្នុងរយៈពេលយូរអង្វែងទៅមុខទៀតនេះ គឺជាការមួយដែលយើងគិតគូរធ្វើបន្តទៀតជុំវិញកំណែទម្រង់ផ្នែកនីតិកម្មទាក់ទងនឹងការអនុវត្តន៍នានារបស់ការរៀបចំការបោះឆ្នោត ។ អ្វីដែលជាការងាររបស់លោកស្រីបន្ទាប់ពីបានចូលរួមនៅពេលនេះ គឺលោកស្រីនឹងលើកឡើងនូវបញ្ហាទាំងអស់នេះជាមួយនឹង គជប ក្នុងការពិគ្រោះយោបល់បន្ថែមទៀត ។

ចំណុចសំខាន់មួយ គឺអ្នកស្រីបានរៀនសូត្រពីកិច្ចប្រជុំខប់សែលប្រ៉មនេះ អ្នកស្រីនឹងពិចារណាថាតើយើងគួរមានវិធានការ ឬយន្តការណាមួយដើម្បីធ្វើការចែកចាយព័តិមានបានដល់មូលដ្ឋាន ជាពិសេសយើងនឹងគាំទ្រ ឬធ្វើសកម្មភាពយ៉ាងម៉េចដើម្បីបញ្ជាក់ឱ្យបានច្បាស់ពីថ្នាក់មូលដ្ឋានវិញ ព្រោះកន្លងមកមានធ្វើតែនៅថ្នាក់ជាតិ ឯការងារចុះមកតាមមូលដ្ឋានថ្នាក់ខេត្តនានាយើងមិនទាន់បានផ្តោតជាសំខាន់ ។

លោក **Larry Strange** បានមានប្រសាសន៍ថា ការដែលលោកមកអង្គុយនៅទីនេះគឺក្នុងនាមលោកជាជនបរទេសមកពីប្រទេសអូស្ត្រាលី ហើយលោកមកធ្វើការនៅប្រទេសកម្ពុជានេះជាង៣ឆ្នាំហើយ ។ ប្រទេសអូស្ត្រាលីជាប្រទេសមួយដែលអនុវត្តធម្មនុញ្ញដែលប្រកបដោយប្រជាធិបតេយ្យ ។ តាមរយៈការសិក្សាអាចបង្ហាញថា ដើម្បីធ្វើឱ្យបាននៅស្ថាប័នមួយដ៏រឹងមាំ និងប្រកប

ដោយលទ្ធិប្រជាធិបតេយ្យ សំរាប់ប្រទេសអូស្ត្រាអីត្រូវការពេលវេលាយូរអង្វែង ហើយការងារទាំងអស់នេះត្រូវការធ្វើជាបណ្តើរៗ ពីមួយជំហ៊ានទៅមួយជំហ៊ាន ។ ដើម្បីធានាថារាល់ការបង្កើតឡើងឱ្យមានស្ថាប័នដ៏រឹងមាំនេះ គឺទទួលបានការគោរព ការអនុវត្ត និងចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងនេះហើយជាគោលបំណងដ៏សំខាន់របស់យន្តការខប់សែលទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត ។

លោក **ឳក សេរី សោភក្តិ៍** សូមថ្លែងអំណរគុណដល់អង្គប្រជុំទាំងមូលដែលបានចំណាយពេលចូលរួមយ៉ាងសស្រាក់សស្រាំនៅក្នុងការផ្តល់មតិ នេះមិនមែនយើងចប់ទេចំណុចទាំងប៉ុន្មានដែលអង្គប្រជុំបានលើកឡើង លោកសង្ឃឹមថានឹងបន្តពិភាក្សាគ្នា រវាងតួអង្គទាំងអស់ដែលចូលរួមនៅក្នុងការបោះឆ្នោត ជាមួយនិងលោកប្រធានលេខាធិការ ដើម្បីជួយពិចារណា ដើម្បីឱ្យការបោះឆ្នោតនៅខេត្តក្រចេះបានប្រកបទៅដោយសុវត្ថិភាព គ្មានការគំរាមគំហែង និងស្ថិតនៅក្នុងលក្ខណៈច្បាប់ ។ ជាបន្ថែមនៅពេលដែលយើងក្រលេកមើលជុំវិញខ្លួន ឧទាហរណ៍នៅក្នុងកន្លែងប្រជុំនេះ មានតុ កង្ហារ ភ្លើង មានបន្ទប់សំរាប់ជជែកគ្នា ទាំងអស់នេះយើងប្រើពេលសឹងតែ ១០ឆ្នាំទំរាំតែបាន ហើយទាំងអស់នេះស្ថិតនៅក្នុងលក្ខណៈវង្វង់នៃអភិបាលកិច្ចល្អ និងលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែបើសិនជាយើងដើរខុស បានន័យថាយើងបោះចោលនូវវប្បធម៌ជជែកពិភាក្សាគ្នា ហើយឈានទៅរកវប្បធម៌អំពើហិង្សា អ្វីៗទាំងអស់នឹងរលាយបាត់អស់ ហើយមិនងាយនិងកសាងបានឡើងវិញទៀតទេ ។ អញ្ចឹងហើយបានជាយន្តការខប់សែលជាស្នូលដើម្បីធ្វើយ៉ាងណាឱ្យនៅពេលដែលមានបញ្ហាម្តងៗ មានតែការជជែកគ្នាត្រង់ទៅត្រង់មកទើបអាចដោះស្រាយបញ្ហាបាន បើយើងងាកចេញពីផ្លូវនេះ គឺយើងងាកចេញទៅយុគសម័យងងឹតម្តងវិញទៀត ហើយកូនចៅជំនាន់ក្រោយអាចនឹងមានបញ្ហា ។

ជាចុងក្រោយលោកបានសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងទេវតាទាំងមួយម៉ឺនលោកធាតុ ជួយថែរក្សាលោកស្រីអស់លោក និង មិត្តភ័ក្រ្តបរទេសដែលមកជួយខ្មែរ បានប្រកបតែសេចក្តីសុខ និងពុទ្ធពរទាំង ៥ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈកុំបីឃ្លៀងឃ្លាតឡើយ ។